01354891

**E1/460.1**


**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber
Chambre de Premiere instance


**ឯកសារដើម**
**ORIGINAL/ORIGINAL**
ថ្ងៃ ខែ ឆ្នាំ (Date): 23-Nov-2016, 15:33
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៦**

**ម៉ោង ០៩:០០នាទី**

**សវនាការលើកទី៤៤១**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម យ៉ា សុខន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ស្តាវរ៉ូឡា ប៉ាប៉ាដូប៉ូឡូស
*(Ms Stavoroula PAPADOPOULOS)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ផវ័ន្ត

លោក សេង លាង

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោកស្រី ជេត វណ្ណលី

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោកស្រី ស្វ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម យ៉ា សុខន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ស្វ៊យ សៅ (2-TCW-1029) | ខ្មែរ |
| លោក ជិន ហែមវិចិត្រ (បុគ្គលិកគាំពារសាក្សី) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី: លោក ស៊ុយ សៅ** (2-TCW-1029)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........................................ ទំព័រ ២

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី........................................ ទំព័រ ៥

សួរដោយលោក ឌេល លីសាក់ ផ្ដើមពី ........................................ ទំព័រ ៣៣

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៨:៥៩:៣៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះ ប្រកាសបន្តកិច្ចដំណើរការនិតិវិធីសវនាការ។ នៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី ដែលមានរហស្សនាម 2-TCW-1029។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលទាំងឡាយដែលអង្គជំនុំជម្រះកោះអញ្ជើញឱ្យចូលរួមក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ។ សូមអញ្ជើញ!

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នេះរឿងក្តីនេះ មានវត្តមាន។ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយសាក្សីដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ មានរហស្សនាម 2-TCW-1029។ សាក្សីបានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែកកាលពីម្សិលមិញនេះ។ ហើយសាក្សីរូបនេះ មានវត្តមាននៅបន្ទប់រង់ចាំរង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ នៅថ្ងៃនេះដែរ មិនមានសាក្សីបម្រុងនោះទេ។

សូមអរគុណលោកប្រធាន។

[០៩:០១:១១]

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីក្រឡាបញ្ជី។

ជាដំបូងអង្គជំនុំជម្រះ សម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះ បានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឱ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៦។ មេធាវីការពារក្តីរបស់ខ្លួន បានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់នឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៦ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា ថ្ងៃនេះ មានអាការៈឈឺខ្នង ឈឺចង្កេះរ៉ាំរ៉ៃ ហើយអង្គុយយូរមិនបាន និងបានផ្តល់អនុសាសន៍ថា សូមឱ្យអង្គជំនុំជម្រះ អនុញ្ញាតឱ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឱ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

[០៩:០២:៥៤]

បង្គាប់ឱ្យបុគ្គលិកផ្នែកសោតទស្សនទ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

បង្គាប់ឱ្យមន្ត្រីរដ្ឋបាលតុលាការ អញ្ជើញសាក្សី 2-TCW-1029 មកកាន់កន្លែងផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តី លោកសាក្សី តើលោកសាក្សីឈ្មោះអីដែរ?

01354897



**លោក ស៊្វយ សៅ៖**

**ឆ៖** --

**ស៖** សាក្សី ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការចេញភ្លើងក្រហមសិន ចាំលោកឆ្លើយ។

**ឆ៖** បាទ ខ្ញុំឈ្មោះ ស៊្វយ សៅ។

**ស៖** លោកកើតនៅថ្ងៃណា ខែណា ឆ្នាំណាដែរ?

**ឆ៖** កើតនៅឆ្នាំ១៩៥៦។

**ស៖** សព្វថ្ងៃលោកប្រកបមុខរបស់អីដែរ?

**ឆ៖** ធ្វើស្រែ។

**ស៖** ឪពុកម្ដាយបង្កើតរបស់លោកឈ្មោះអីដែរ?

**ឆ៖** ឈ្មោះ ស៊្វយ ហេង។

**ស៖** ប្រពន្ធលោកឈ្មោះអី ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** --

**ស៖** ចាំឆ្លើយម្ដងទៀត នៅពេលមីក្រូហ្វូនប្រតិបត្តិការ។

**ឆ៖** ឈ្មោះ ចាយ អ៊ូយ កូនមានប្រាំមួយនាក់។

**ស៖** អរគុណលោក ស៊្វយ សៅ។ តាមរបាយការណ៍របស់ក្រឡាបញ្ជីបានបញ្ជាក់ថា តាមសមត្ថភាព និង លទ្ធភាពដែលលោកអាចដឹង គឺលោកមិនមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប លោក នួន ជា និង ខៀវ សំផន និងបុគ្គលដែលត្រូវបានទទួលជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ នេះទេ។ តើពិតមែនទេ?

[០៩:០៦:៣៦]

**ឆ៖** ពិតមែនហើយ។

**ស៖** ហើយថា លោកបានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែក មុនចូលមកនៅចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ តើពិតជាអ៊ីចឹងមែនទេ?

**ឆ៖** បាទ ពិតមែនហើយលោកប្រធាន។

**ស៖** បាទអរគុណ។ ជាបន្តទៅនេះ យើងប្រាប់អំពីសិទ្ធិ និង ករណីយកិច្ចដល់លោក ក្នុងឋានៈលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ -- អំពីសិទ្ធិ ក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរការ

នីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការដែលឲ្យលោកធ្វើអត្ថាធិប្បាយមួយ ឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

អំពីករណីយកិច្ច ក្នុងឋានៈលោកជាសាក្សី លោកត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតបរបស់លោក ឬការធ្វើអត្ថាធិប្បាយរបស់លោកនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់អំពីសិទ្ធិរបស់លោករួចហើយអម្បាញ់មិញនេះ។ ក្នុងឋានៈជាសាក្សីលោកត្រូវតែឆ្លើយឲ្យការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នៅព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរ ដែលភាគីសួរចំពោះលោក។ លោក ស៊្លុយ សៅ តើលោកដែលផ្តល់សក្ខីកម្ម ឬផ្តល់កិច្ចសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ កន្លងមក ហើយប្រសិនបើមានធ្វើ ធ្វើប៉ុន្មានដង នៅកន្លែងណា?

[០៩:០៨:២៩]

**ឆ៖** បាទ ខ្ញុំសម្ភាសម្តងនៅអីភូមិខ្ញុំនុ៎ងឯង។

**ស៖** អរគុណ ហើយនិងមុនពេលចូលចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានពិនិត្យមើល ឬបានអាននៅកំណត់ហេតុដែលលោកបានផ្តល់ចម្លើយកាលពីពេលមុនជាមួយនឹងអ្នកស៊ើបអង្កេត នៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលបានរំឭកការចងចាំដែរឬទេ?

**ឆ៖** បាទ ខ្ញុំបានអាន មើលហើយ។

**ស៖** ហើយតាមសមត្ថភាពដែលលោកអាចដឹងបាន តើលោកអាចបញ្ជាក់បានដែរទេថា កំណត់ហេតុស្តាប់ចម្លើយដែលលោកបានអាន ដើម្បីរំឭកការចងចាំហ្នឹងវាពិតជាត្រឹមត្រូវ វាស៊ីសង្វាក់គ្នា ស្របទៅនឹងចម្លើយដែលលោកបានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលមុនដែរឬទេ?

**ឆ៖** បាទ ស្របគ្នាបាទ។

**ស៖** អរគុណលោកសាក្សី។

**ប្រធានអង្គជំនុំ៖**

ក្នុងការសួរដេញដោលសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិ ៩១ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក

អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅលោកមេធាវីការពារក្តីលោក នួន ជា សួរដេញដោលសាក្សី ស៊្វយ សៅ នេះ មុនភាគីដទៃទៀត នៃរឿងក្តី ហើយមេធាវីការពារក្តីលោក នួន ជា មានរយៈពេលមួយវគ្គនៃថ្ងៃសវនាការ។ សូមអញ្ជើញលោក។

[០៩:០៩:៥៨]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម សហការីទាំងអស់ ជម្រាបសួរលោកសាក្សី។ លោកប្រធាន សូមជម្រាបថាមេធាវីការពារក្តីមានពីរវគ្គ ខ្ញុំនឹងប្រើប្រាស់ពេលវេលាភាគច្រើននៃវគ្គទី២ផងដែរ ដែលជាពេលវេលាសម្រាប់ក្រុមមេធាវីការពារក្តី ខៀវ សំផន ក្រោយពេលដែលដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងសហព្រះរាជអាជ្ញាបញ្ចប់ការតាំងសំណួររបស់ខ្លួន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ អរុណសួស្តីសាជាថ្មីលោកសាក្សី។ លោកធ្លាប់ត្រូវបានសម្ភាសមួយដងដែរ ហើយតាមពិតទៅមន្ត្រីស៊ើបអង្កេតរបស់តុលាការយើងនេះមិនបានសម្ភាសលោកទេ ក៏ប៉ុន្តែ គឺអង្គការដែលឈ្មោះថា ឌី.ស៊ី.ខេម (មជ្ឈមណ្ឌលឯកសារកម្ពុជា)ទេ ដែលសម្ភាសលោក អ៊ីចឹងមែនទេ?

**លោក ស៊្វយ សៅ៖**

**ឆ៖** បាទ អារឿងនោះ ខ្ញុំវាមិនដឹងដែរ។

[០៩:១១:០៨]

**ស៖** បាទ មិនថ្វីទេ។ ឥឡូវនេះ ខ្ញុំសូមចូលទៅសួរលោកអំពីរយៈពេល<មុនថ្ងៃ១៧ មេសា>ឆ្នាំ<៧៥> តើលោកអាចជម្រាបជូនតុលាការបានទេ ថាលោកបានចូលធ្វើបដិវត្តន៍ ចូលរួមជាមួយបដិវត្តន៍នៅពេលណាដែរ?

**ឆ៖** បាទ តាំងពី៧២។

**ស៖** ហើយតើលោកចូលបដិវត្តន៍នៅកន្លែងណាដែរ?

**ឆ៖** ចូលនៅឯភូមិចំបក់បញ្ញា។

**ស៖** តើលោកនៅនឹកឃើញទេថានៅក្នុងឆ្នាំ១៩៧២ ឬក៏៧៣ហ្នឹង លោកចំណុះឲ្យកងពលណាដែរ លោកជាសមាជិកនៃកងទ័ពបដិវត្តន៍ហ្នឹងចំណុះឲ្យកងពលណាដែរ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** កងពល៣១០។

**ស៖** តើត្រឹមត្រូវទេដែលថាកងពល៣១០ ត្រូវបានគេហៅថាជាកងពលលេខ១ មុនពេលរំដោះ តើត្រឹមត្រូវដែរទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** តើត្រឹមត្រូវដែរទេចុះដែលលោក គឺជាកងទ័ពចំណុះឲ្យកងវរសេនាធំលេខ១៤ <នៃកងពលលេខ១>?

**ឆ៖** វរសេនាតូច -- វរសេនាធំ១១។

**ស៖** តើលោកយល់ស្របជាមួយខ្ញុំដែរថា ទី១កងពល៣១០ហ្នឹងពីមុនហ្នឹងគឺជាកងពលលេខ១ទេ <តើ>មានកងពល<>លេខ២<ដែរទេមុនពេលរំដោះ>?

**ឆ៖** បាទ ខ្ញុំអានោះ ក៏មិនយល់ដែរ។

**ស៖** តើលោកធ្លាប់ឮសួរកងពលមួយ<គេហៅថា>កងពលលេខ៩២០ដែរទេ?

**ឆ៖** អត់ធ្លាប់ផង។

**ស៖** តើត្រឹមត្រូវដែរទេដែលថាកងពលលេខ១ គឺជាផ្នែកមួយនៃភូមិភាគឧត្តរ?

**ឆ៖** បាទ ត្រឹមត្រូវហើយ ភូមិភាគឧត្តរនោះឯង។

**ស៖** តើលោកនៅនឹកឃើញទេ អ្នកណាជាប្រធានភូមិភាគឧត្តរនោះមុនឆ្នាំ១៩៧៥?

[០៩:១៤:៥៦]

**ឆ៖** តាវឿង។

**ស៖** ខ្ញុំខ្លាចតែស្ដាប់ការបកប្រែមិនបានច្បាស់។ តើលោកកំពុងតែនិយាយ តាហឿន ឬតាវឿង ឬក៏ កុយ ធួន?

**ឆ៖** តាវឿង នោះមេកងពលទី១ ខាងឧត្តរនោះឯង ៣១០ហ្នឹងឯង។

**ស៖** បាទ ឥឡូវខ្ញុំយល់ហើយលោកនិយាយអំពី តាអឿន <>ដែលជាមេកងពលលេខ១ ឬក៏ហៅថា ជាកងពល៣១០ ក្រោយមក។ តែសំណួរខ្ញុំសួរថា តើអ្នកណាជាមេភូមិភាគឧត្តរ ជាប្រធានភូមិភាគឧត្តរ លោកស្គាល់ទេ?

**ឆ៖** បាទ ខ្ញុំអត់ស្គាល់ផង។

**ស៖** ខ្ញុំនឹងត្រឡប់មកសួរលោកអំពីចំណុចនេះនៅពេលក្រោយ។ តើលោកនៅនឹកឃើញអំពីការ

វាយប្រហារនៅទីក្រុងភ្នំពេញនៅក្នុង<ខែមេសា>ឆ្នាំ១៩៧៥ ដែរឬទេ? ហើយបើមានមែននោះ តើលោកមានចូលរួមក្នុងការវាយប្រយុទ្ធនេះដែរទេ?

**ឆ៖** បាទ ខ្ញុំចូលរួមជាមួយ តារឿង នេះឯង។

**ស៖** ហើយតើត្រឹមត្រូវដែរទេ ដែលថាលោកបានចូលមកភ្នំពេញ នៅក្នុងឆ្នាំ៧៥ ជាមួយកងពលលេខ១ គឺមកពីកំពង់ធំមក លោកនឹកឃើញទេ?

**ឆ៖** ថា ខ្ញុំនឹកមិនឃើញទេ វាភ្លេចភ្លាំងអស់ហើយ។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានទេ ថាលោកបានធ្វើអ្វីដែរ ក្រោយរំដោះទីក្រុងភ្នំពេញ នៅខែមេសា ១៩៧៥។ តើលោកឈរជើងនៅទីណាក្រោយខែមេសា ១៩៧៥? ហើយលោកធ្វើអ្វី?

**ឆ៖** បាទ ខ្ញុំឈរជើងនៅទួលគោក។

[០៩:១៧:៣៨]

**ស៖** នៅទួលគោកហ្នឹង នៅចំកន្លែងណាដែរ លោកដឹងដែរ?

**ឆ៖** នៅជិតវ៉ារទេះភ្លើង។

**ស៖** តើកងពល៣១០ មានទីបញ្ជាការរបស់ខ្លួននៅទួលគោក ឬក៏នៅក្បែរវត្តភ្នំ ឬក៏នៅកន្លែងណាមួយក្នុងទីក្រុងភ្នំពេញ?

**ឆ៖** ខ្ញុំនៅឈរជើងឯទួលគោកហ្នឹងឯង បានគេដកទៅកប់ស្រូវវិញ។

**ស៖** ចុះគេបញ្ជូនលោកទៅកប់ស្រូវហ្នឹងនៅពេលណា?

**ឆ៖** ពេលដែលនេះទៅ ឆ្នាំប៉ុន្មានទេ ខ្ញុំភ្លេចបាត់ហើយ។

**ស៖** ចុះលោកធ្វើអ្វីដែរនៅឯកប់ស្រូវនោះ?

**ឆ៖** ទៅធ្វើស្រែ។

**ស៖** ចុះលោកនៅធ្វើស្រែនៅឯកប់ស្រូវនោះ អស់រយៈពេលប៉ុន្មានដែរ?

**ឆ៖** អស់ពេលរយៈមួយឆ្នាំ។

**ស៖** ហើយបន្ទាប់មក គេបញ្ជូនលោកទៅណាទៀត?

**ឆ៖** គេបានចេញពីកប់ស្រូវទៅ ទៅវ៉ៃនឹងកងទ័ពវៀតណាមនៅខាងណោះកំពង់ចាម។

**ស៖** ហើយក្រោយពេលប្រយុទ្ធគ្នាជាមួយនឹងវៀតណាមរួចមក តើលោកធ្វើអ្វីទៀត?

**ផ៖** ខ្ញុំគេដកមកឲ្យនៅតាមភូមិវិញ។

**ស៖** តើត្រឹមត្រូវដែរឬទេ ដែលថានៅពេញអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ លោកគឺថាធ្វើជាកងទ័ពពេញមួយរបបនោះតែម្តង ត្រឹមត្រូវដែរទេ?

**ផ៖** ត្រឹមត្រូវ។

**ស៖** តើក្នុងពេញមួយរបបហ្នឹង មានពេលណាមួយលោកមានឋានៈ ឡើងឋានៈណាមួយដែរ ពេលលោកនៅកងពល៣១០? ឬក៏លោកធ្វើតែយុទ្ធជនសុទ្ធសាធរហូតតែម្តង?

[០៩:២០:៣៩]

**ផ៖** បាទ ខ្ញុំនៅតែយុទ្ធជនដដែលហ្នឹងឯង បាទ។

**ស៖** លោកសាក្សី តើលោកចេះអាន ចេះសរសេរដែរទេ?

**ផ៖** ចេះតិចៗ។

**ស៖** ខ្ញុំសុំឲ្យលោកពិនិត្យមើលបញ្ជីឈ្មោះមនុស្ស ហើយចង់ដឹងមើលថា តើលោកស្គាល់អ្នកណាខ្លះដែរឬក៏អត់?

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធានសុំការអនុញ្ញាតបញ្ជូនឯកសារ គឺឯកសារ E3/1585។ បាទ ឯកសារនេះគឺជាបញ្ជីអ្នកចូលរួមនៅវគ្គរៀនសូត្រអគ្គសេនាធិការថ្ងៃទី២០ តុលា ៧៦ ERN អង់គ្លេស 00897650 ដល់ 51, ខ្មែរ 00095533 ដល់ 34, បារាំង 00611636។ បាទ លោកប្រធាន សុំការអនុញ្ញាតបង្ហាញឯកសារនេះ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការ យកឯកសារនេះយកទៅជូនសាក្សី។

[០៩:២២:៤៣]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំនឹងអានឈ្មោះមនុស្សទាំងនេះឲ្យលោកស្តាប់ ដើម្បីឲ្យលោកតាមខ្ញុំទាន់។ លោកសាក្សី ឈ្មោះដែលខ្ញុំ *ហាយឡាយ* ទី១នោះគឺ ឈ្មោះដែលលោកលើកយកមកនិយាយហើយគឺ សមមិត្តអឿន ។ បាទ ក្នុងបញ្ជីនេះ គេដាក់ថា គាត់ជាលេខាកងពល៣១០។ លេខរៀងទី២ នៅមើល -- លេខលើបញ្ជីគឺ សមមិត្តរឿង។ តើលោកស្គាល់ សមមិត្ត រឿង ទេ?

**លោក ស៊្វីយ សៅ៖**

**ឆ៖** បាទ ស្គាល់តែ រឿង សព្វថ្ងៃ។

**ស៖** តើ រឿង នេះជាអ្នកណាដែរ លោក?

**ឆ៖** ជានាយកងពល។

**ស៖** លេខរៀងទី៦នៅលើបញ្ជីនេះឈ្មោះ សមមិត្តចាំង -- សមមិត្តចន -- ឆន១ តើលោកស្គាល់ សមមិត្តឆន នេះទេ?

**ឆ៖** បាទ ខ្ញុំអត់ស្គាល់ទេ។

**ស៖** គាត់ជាមេបញ្ជាការវរសេនាធំលេខ១១។ បើសិនណានិយាយពីវរសេនាធំលេខ១១ លោកនឹកឃើញទេ?

**ឆ៖** នឹកមិនឃើញទេ តាំងពីខ្ញុំនៅតូចម្ល៉េះនោះ។

**ស៖** មិនថ្វីទេ លោកសាក្សី។ លេខរៀងទី១៦គឺមេបញ្ជាការវរសេនាធំលេខ១២ឈ្មោះ សមមិត្តថេង -- ផេង នេះ សមមិត្ត ផេង តើលោកស្គាល់ សមមិត្តផេង នេះទេ?

**ឆ៖** មិនស្គាល់ទេ។

**ស៖** លេខរៀងទី២៦ គឺវរសេនា -- មេបញ្ជាការវរសេនាធំលេខ១៣ ឈ្មោះ សមមិត្ត សុង ទេ? ស្គាល់ សមមិត្តសុង នេះដែរទេ លោក?

**ឆ៖** អត់ស្គាល់ផង។

[០៩:២៤:៥៧]

**ស៖** លេខរៀង៣១ សមមិត្តយឹម ជាមេបញ្ជាការ<វរ>សេនាតូច លោកស្គាល់ទេ វរសេនាតូចស្គាល់ទេ?

**ឆ៖** អត់ស្គាល់ផង។

**ស៖** បាទ នៅសល់ឈ្មោះបីនាក់ទៀត លេខរៀង៣៨ សមមិត្ត <ហួន> មេបញ្ជាការវរសេនាតូច៣១១ លោកស្គាល់ទេ?

**ឆ៖** អត់ស្គាល់ផង។

**ស៖** ដល់លេងរៀង៤០ គឺមេបញ្ជាការវរសេនាតូច៣១២ ឈ្មោះសមមិត្ត ម៉ាច ស្គាល់ទេ?

**ឆ៖** អត់ស្គាល់ដែរហ្នឹង។

**ស៖** ហើយឈ្មោះចុងក្រោយជាមេបញ្ជាការវរសេនាតូច៣១៥ ឈ្មោះ ថន លោកស្គាល់ទេ?

**ឆ៖** ហ្នឹងក៏ខ្ញុំមិនស្គាល់ដែរ។

**ស៖** ក្រៅពីមេបញ្ជាការកងពល៣១០ នេះដែលលោកស្គាល់តែ តាអឿន ហើយនិង តារឿង នេះ ក្រៅពីនោះទៀតមេបញ្ជាការ បញ្ជាការរងដទៃទៀតលោកស្គាល់ដែរទេ?

**ឆ៖** ខ្ញុំមិនស្គាល់ទេ។

**ស៖** ឥឡូវ ខ្ញុំសូមសួរឈ្មោះមនុស្សពីរនាក់ទៀត លោកក៏បានលើកឈ្មោះមនុស្សពីរនាក់នេះរួចមកហើយនៅក្នុងចម្លើយរបស់លោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា។ ទី១ គឺឈ្មោះ ចាន់ ចក្រី។ តើលោកស្គាល់ ឬក៏នឹកឃើញមនុស្សម្នាក់ឈ្មោះ ចាន់ ចក្រី ដែរឬទេ?

**ឆ៖** ខ្ញុំឮតែឈ្មោះ។

[០៩:២៧:១៥]

**ស៖** ចុះលោកឮអំពីរឿងអីដែរ? ឮឈ្មោះគាត់គេនិយាយអំពីរឿងអ្វីដែរ?

**ឆ៖** មួយសានោះការវាយប្រហាររបប ប៉ុល ពត ហ្នឹង ទីក្រុងភ្នំពេញ។

**ស៖** ការវាយប្រហារនៅទីក្រុងភ្នំពេញមួយណាដែលលោកកំពុងតែនិយាយនេះ តើលោកនិយាយអំពីការវាយប្រយុទ្ធយកទីក្រុងភ្នំពេញ ខែមេសា ៧៥ ឬក៏ការវាយប្រយុទ្ធមួយណា?

**ឆ៖** តាំងពី៧០ ម្លេះ។

**ស៖** ខ្ញុំត្រឡប់មកសួរលោកអំពី ចាន់ ចក្រី។ សំណួរចុងក្រោយមុននឹងសួរលោកអំពីមនុស្សផ្សេងទៀត។ តើ ចាន់ ចក្រី គាត់ជាកងទ័ពម្នាក់ ឬក៏ក្លាប់កងទ័ពមកពីភូមិភាគឧត្តរ ឬក៏អត់ទេពីដំបូងឡើយមក?

**ឆ៖** ខាងពួកបូព៌ាតើ អ៎! ខាងបូព៌ានេះ កើតនេះ។

**ស៖** បាទ ត្រឹមត្រូវហើយមកពីបូព៌ាមែន។ ប៉ុន្តែលោកដឹងទេថា មុននឹងគាត់ធ្វើជាមេបញ្ជាការកងទ័ពនៅភូមិភាគបូព៌ាហ្នឹង គឺគាត់គឺជាកងទ័ពមកពីភូមិភាគឧត្តរទេ លោកដឹងដែរ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

[០៩:២៨:៥៨]

**ប្រធានអង្គជំនុំ៖**

លោកសាក្សីឆ្លើយម្តងទៀត ព្រោះពេលលោកឆ្លើយអម្បាញ់មិញមីក្រូហ្វូនអត់ទាន់ប្រតិបត្តិការ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទេ។ សូមលោកឆ្លើយ!

**ឆ៖** អត់ដឹងផង។

**ស៖** មិនអីទេ។ ចម្លើយរបស់លោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា លោកលើកឈ្មោះម្នាក់យកមកនិយាយ គឺសម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន។ តើសម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នេះធ្លាប់ជាកងទ័ពមួយចំណុះឱ្យភូមិភាគឧត្ដរដែរឬទេ?

**ឆ៖** ខ្ញុំមិនស្គាល់ដែរហ្នឹង។

**ស៖** ខ្ញុំសូមសួរបញ្ចប់ត្រង់ចំណុចនេះ លោកសាក្សី។ យើងមានសាក្សីម្នាក់មកផ្ដល់សក្ខីកម្មចំពោះមុខតុលាការយើង នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៥។ គាត់ជាយុទ្ធជនម្នាក់មកពីកងពល៣១០។ គាត់ឈ្មោះ សែម ហឿន។ ហើយនៅម៉ោង១៥:២៧ គាត់បានឆ្លើយថា "ខ្ញុំបានឃើញ ហ៊ុន សែន ជាកងទ័ពចំណុះឱ្យកងពល៣១០ នៃភូមិភាគឧត្ដរកាលនោះ។ អង្កាល់ដែលខ្ញុំឃើញគាត់ហ្នឹង គឺគាត់ហ្នឹងគឺថាហើយជាកងទ័ពចំណុះឱ្យកងពល៣១០ហើយ"។ តើលោកយល់ដូចម្ដេចដែរ ឬក៏លោកមានប្រតិកម្មយល់យ៉ាងម៉េចដែរ ចំពោះសក្ខីកម្មរបស់សាក្សីរូបនេះ?

**ឆ៖** បាទ បើខ្ញុំមិនដឹង។

[០៩:៣១:០៦]

**ស៖** បាទ ខ្ញុំនឹងត្រឡប់មកសួរចំណុចនេះ នៅពេលក្រោយទៀត។ លោកសាក្សី ពីខាងដើមនេះខ្ញុំបានសួរទៅលោកថា តើអ្នកណាជាអតីតប្រធានភូមិភាគឧត្ដរ មុនឆ្នាំ៧៥? ចុះបើខ្ញុំនិយាយពីឈ្មោះមនុស្សម្នាក់ថា ឈ្មោះ កុយ ធួន ឬក៏ ឃួន តើលោកនឹកឃើញ ឬក៏ស្គាល់ដែរទេ?

**ឆ៖** បាទ បើខ្ញុំមិនស្គាល់នោះ។

**ស៖** បាទ ឈ្មោះមនុស្សចុងក្រោយ<មិនមែន>មកពីខាងកងទ័ព<ទេ គឺ>ឈ្មោះ តុល តើលោកស្គាល់ទេ?

**ឆ៖** មិនស្គាល់ទេ ខ្ញុំនោះ។

**ស៖** បាទ មិនថ្វីទេ លោកសាក្សី។ ឥឡូវ យើងចូលទៅប្រធានបទដ៏សំខាន់មួយ។ លោកបានឆ្លើយថា មេបញ្ជាការកងពល៣១០ គឺតាអឿន។ តើមានអ្វីកើតឡើងចំពោះ តាអឿន លោកដឹងដែរឬទេ?

**ឆ៖** បាទ គេចាប់យក។

**ស៖** ហេតុអ្វីបានជាគេចាប់គាត់?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** គាត់ធ្វើការដួលរលំសម័យនោះឯង។

**ស៖** តើឲ្យពិតប្រាកដទៅ តើតាអឿន ធ្វើសកម្មភាពអ្វីដែរ ក្នុងការរដ្ឋប្រហារនេះ ធ្វើសកម្មភាពអ្វីខ្លះដែរ?

[០៩:៣៣:១៨]

**ឆ៖** វាផ្តួលរំលំរបប ប៉ុល ពត នោះឯង។

**ស៖** តើនៅក្នុងថ្ងៃខែឆ្នាំណាដែរ ដែលតាអឿន មានផែនការផ្តួលរំលំរដ្ឋាភិបាលប៉ុល ពត ហ្នឹង លោកចាំទេ នៅពេលណាដែរ?

**ឆ៖** ពីឆ្នាំ៧៦។

**ស៖** តើពេលនុំងហ្នឹង គឺជាចុងឆ្នាំ៧៦ ឬក៏ថាជាដើមឆ្នាំ១៩៧៧ រយៈពេលទាំងពីរនេះ វាអាចមួយណាបានដែរឬទេ?

**ឆ៖** ពាក់កណ្តាលឆ្នាំ។

**ស៖** បាទ ខ្ញុំសូមសួរតាមរបៀបផ្សេង។ តើឲ្យជាក់លាក់ទៅ តាអឿន និងអ្នកដទៃទៀត ត្រូវបានគេចាប់ខ្លួន នៅពេលណាដែរ?

**ឆ៖** ខ្ញុំអត់ចំណាំផង។

**ស៖** ចុះបើខ្ញុំនិយាយថា តាអឿន ហើយនិងអ្នកដទៃទៀតត្រូវចាប់ខ្លួននៅក្នុងខែ<កុម្ភៈ> ឆ្នាំ ១៩៧៧ តើលោកនឹកឃើញទេ?

[០៩:៣៤:៥៩]

**ឆ៖** នឹកមិនឃើញទេ ព្រោះខ្ញុំក្មេងដែរ។

**ស៖** មិនថ្វីទេលោកសាក្សី។ លោកបានឆ្លើយអំពីការធ្វើរដ្ឋប្រហារទម្លាក់រដ្ឋាភិបាល<> តើអ្វីដែលជាផែនការរបស់ តាអឿន ហើយតើអ្វីបានកើតមានឡើងនៅពេលដែលគាត់មានផែនការធ្វើរដ្ឋប្រហារហ្នឹង តើលោកអាចជម្រាបជូនអំពីសកម្មភាពណាមួយជូនតុលាការបានទេ?

**ឆ៖** ខ្ញុំជម្រាបមិនបានទេ ព្រោះខ្ញុំមិនដឹង។

**ស៖** បាទ ឥឡូវខ្ញុំសូមព្យាយាមបន្តិចមើលក្រែងលោអាចជួយរំឭកការចងចាំរបស់លោកបាន។ តើលោកនឹកឃើញ នៅនឹកឃើញទេ ថាមានអង្គប្រជុំមួយ តាអឿន ជាអ្នករៀបចំ ដែលក្នុងអង្គប្រជុំនេះ គាត់បាននិយាយអំពីការវាយដណ្តើមយកទីក្រុងភ្នំពេញ។ លោកនឹកឃើញអំពីអង្គប្រជុំមួយនេះទេ?

[០៩:៣៦:១៩]

**ធ៖** ខ្ញុំរកនឹកមិនឃើញទេ ព្រោះខ្ញុំនៅក្រៅណោះ។

**ស៖** តើលោកដឹងថាមានយុទ្ធជនពីកងពល៣១០ ចូលរួមនៅក្នុងការធ្វើរដ្ឋប្រហារនេះដែរឬទេ ហើយបើមានយុទ្ធជនមកពីកងពល៣១០មែននោះ តើមានប៉ុន្មាននាក់ដែរ?

**ធ៖** កម្លាំងប្រហែល១០០ហ្នឹងទេ។

**ស៖** តើលោកមានភារកិច្ចអ្វីជាក់លាក់ដែរទេនៅក្នុងផែនការធ្វើរដ្ឋប្រហារដណ្តើមយកទីក្រុងភ្នំពេញនេះ?

**ធ៖** ខ្ញុំមនុស្សខ្ញុំមិនដឹងដែរ ស្រេចនឹងកងពលនោះឯង។

**ស៖** តើលោកមានជាប់ពាក់ព័ន្ធភារកិច្ចក្នុងការដឹកជញ្ជូនអាវុធពេញៗឡានចូលមកទីក្រុងភ្នំពេញ ដើម្បីមកជួប តាអឿន នៅភ្នំពេញធ្វើការវាយប្រហារនេះដែរឬទេ?

**ធ៖** ខ្ញុំកូនទាហានគេ ត្រៀមកម្លាំងអ៊ីចឹង គាត់ធ្វើម៉េច មិនដឹង ខ្ញុំក៏មិនដឹងដែរ។

**ស៖** តើលោកដឹងថាមានកងទ័ពពិសេសណាមួយចូលរួមពាក់ព័ន្ធនៅក្នុងការវាយប្រយុទ្ធទីក្រុងភ្នំពេញនេះដែរទេ?

**ធ៖** មានគេខាងបូព៌ានុ៎ងឯង។

[០៩:៣៨:២៨]

**ស៖** ខ្ញុំនឹងមកសួរលោកចំណុចនេះនៅពេលក្រោយដែរ លោកសាក្សី។ ប៉ុន្តែតើមានកងពិសេស ឬក៏ក្រុមពិសេសដែលចំណុះឲ្យកងពល៣១០ហ្នឹងមកចូលរួមក្នុងផែនការវាយ<ប្រហារ>ទីក្រុងភ្នំពេញ <ឬ> ប៉ុល ពត នេះដែរឬទេ?

**ធ៖** អានោះ ខ្ញុំមិនដឹងដែរ។

**ស៖** បាទខ្ញុំសូមព្យាយាមសាកល្បង ក្រែងអាចជួយរំឭកដល់ការចងចាំរបស់លោកបាន។

ចម្លើយរបស់លោកគឺ E3/7535 ឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា អង់គ្លេស 00324168, ខ្មែរ 00087817, បារាំង 00324206។ “តាអឿន បានធ្វើការផែនការធ្វើរដ្ឋប្រហារ ប៉ុន្តែជាអកុសល នៅពេលវាបែកការណ៍ទៅតីយើង គេបញ្ជូនពួកយើងឲ្យទៅធ្វើស្រែមួយរយៈ។ សួរ៖ តើលោកអាចរៀបរាប់អំពីផែនការរបស់ តាអឿន នេះបានទេ? ឆ្លើយ៖ ទី១ គាត់ហៅយើងទៅឲ្យប្រជុំស្ងាត់ៗ ហើយណែនាំយើងថា គាត់មានផែនការវាយដណ្តើមយកទីក្រុងភ្នំពេញ។ គាត់ប្រាប់ថានឹងរំដោះយកទីក្រុង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ភ្នំពេញ ត្រួតត្រាទីក្រុងភ្នំពេញតែម្តង។ សួរ៖ តើ តាអឿន មានបើកអង្គប្រជុំជាមួយអតីតទ័ពគាត់មុនទេ? ឆ្លើយ៖ បាទ គឺមានទ័ពតែ១០០នាក់ទេ រួមនោះមានខ្ញុំផងដែរ ដែលត្រូវបានហៅទៅឲ្យប្រជុំស្ងាត់ៗនេះ។ សួរ៖ ហើយចុះលោកចូលរួមដែរឬទេ? ឆ្លើយ៖ ខ្ញុំគឺថាដឹកអាវុធពេញឡានមកភ្នំពេញ ដើម្បីរៀបចំធ្វើការវាយដណ្តើមយកទីក្រុងភ្នំពេញ ក៏ប៉ុន្តែអកុសលគឺថាផែនការនោះក៏បែកការណ៍ទៅ។ សួរ៖ តើ <លោកមានតួនាទីអីក្នុង>កងទ័ពទាំង១០០នាក់ហ្នឹង<>? ឆ្លើយ៖ <ជាយុទ្ធជន ប៉ុន្តែ>គឺថាគេ<បាន>ជ្រើសរើសកងពិសេស តែកងពិសេសប៉ុណ្ណោះ ដើម្បីវាយដណ្តើមទីក្រុងភ្នំពេញ។ សួរ៖ ទាំង១០០នាក់ហ្នឹងឬ ដែលជាអ្នកពិសេសនោះ? ឆ្លើយ៖ បាទ<យើងបានត្រៀមខ្លួនរួចហើយ ដើម្បីការប្រយុទ្ធនោះ>។ សួរ៖ <>តើ<នោះជាកង>ប្រយុទ្ធ<ឬ>? ឆ្លើយ៖ កងកម្លាំង -- វាៗមានកងកម្លាំងប្រយុទ្ធ កងកម្លាំងការពារ យើងទទួលបានគ្រឿងសព្វាវុធពីប្រទេសក្រៅមក។" បញ្ចប់ការដកស្រង់។

លោកសាក្សី នេះគឺជាចម្លើយរបស់លោកដែលលោកបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា។ តើវាពិតជាត្រឹមត្រូវយ៉ាងដូច្នេះមែនឬទេ?

[០៩:៤១:២៣]

**ឆ៖** បាទ ពិតមែននេះឯង។

**ស៖** លោកបាននិយាយអំពីផែនការវាយប្រយុទ្ធដណ្តើមយកទៅក្រុងភ្នំពេញ។ តើលោកនៅនឹកឃើញទេ មានគោលដៅណាជាក់លាក់ដែលគេត្រូវវាយដណ្តើមយកនោះដែរទេនៅក្នុងក្របខ័ណ្ឌ មានន័យថា នៅក្នុងការធ្វើរដ្ឋប្រហារនេះមានមុខព្រួញណាសំខាន់ៗ ដែលគេត្រូវច្បាមយកជាមុនដែរទេ?

**ឆ៖** វាយរំលំ ពួក ខៀវ សំផន ហ្នឹង បាទ។

**ស៖** បាទ ទុករឿងនេះម្តុំទៅ។ សំណួរខ្ញុំមិនសួរពីមនុស្សទេលោក ខ្ញុំសួរអំពីទីកន្លែងនៅក្នុងទីក្រុងភ្នំពេញ។ តើ តាអឿន មានគំនិតយោបល់ មានផែនការក្នុងការវាយដណ្តើមយកកន្លែងជាក់លាក់មួយចំនួននៅក្នុងទីក្រុងភ្នំពេញសិនដែរឬទេ?

**ឆ៖** នោះឯង ខ្ញុំក៏មិនដឹងដែរ តាមមេគាត់បញ្ជាដែរ។

**ស៖** តើ តាអឿន មាននិយាយអំពីកងនានា ចំណុះឲ្យកងពល៣១០ដែលត្រូវវាយប្រយុទ្ធ និងដណ្តើមយកព្រលានយន្តហោះពោធិ៍ចិនតុងដែរឬទេ?

**ឆ៖** នោះ ខ្ញុំបាទក៏មិនដឹងដែរ។

**ស៖** ចុះលោកឮ តាអឿន និយាយអំពីការវាយប្រយុទ្ធដណ្តើមកាន់កាប់ស្ថានីយវិទ្យុផ្សាយ

សំឡេងនៅទីក្រុងភ្នំពេញដែរឬទេ?

[០៩:៤៣:៤១]

**ផ៖** ខ្ញុំមិនដែលឮទេ ព្រោះខ្ញុំកូនទាហានគាត់ដែរ។

**ស៖** ដូច្នេះ ភារកិច្ចរបស់លោក គឺដឹកអាវុធតាមរយៈឡានកាមីញ៉ុងនេះចូលយកមកទីក្រុងភ្នំពេញតែប៉ុណ្ណោះឯង។ នេះជាភារកិច្ចតែមួយគត់របស់លោក អ៊ីចឹងមែនទេ?

**ផ៖** បាទ។

**ស៖** លោកក៏បាននិយាយអំពី -- បាទ នេះគឺនៅក្នុងចម្លើយឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលលោកបានឆ្លើយ គឺឯកសារ E3/7535, អង់គ្លេស 00324171, ខ្មែរ 00087821, បារាំង 00324210។ បាទ កន្លែងនេះ និយាយអំពីការលាក់អាវុធទុកនៅក្នុងឃ្លាំងមួយ។ តើលោកនៅនឹកឃើញទេ អំពីការលួចលាក់ទុកអាវុធនៅក្នុងឃ្លាំងមួយ ដើម្បីយកទៅប្រើប្រាស់ការវាយប្រយុទ្ធដណ្ដើមយកទីក្រុងភ្នំពេញនៅក្នុងផែនការធ្វើរដ្ឋប្រហារនេះ លោកនឹកឃើញទេ?

**ផ៖** ខ្ញុំនឹកមិនឃើញទេ។

[០៩:៤៥:២៧]

**ស៖** មុននេះ លោកបានបញ្ជាក់អះអាងអំពីចម្លើយរបស់លោក ដែលលោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលខ្ញុំទើបតែអានឲ្យលោកស្ដាប់ ហើយដែលលោកឆ្លើយថា ក៏មានជំនួយពីប្រទេសក្រៅផងដែរ។ ហើយមុននេះ ក៏លោកលើកពីឈ្មោះ ចាន់ ចក្រី ដែលជាកងទ័ពគាំទ្រមួយមកពីខាងភូមិភាគបូព៌ា។ បាទ នៅត្រង់ទំព័រ១៨ នៃចម្លើយរបស់លោក អង់គ្លេស 00324172, បារាំង 00324210 និងខ្មែរ 00087822។ លោកបានឆ្លើយថា "ការវាយរំលំ ប៉ុល ពត មិនជារឿងងាយស្រួលទេ បើ<យើងមិនអាច>វាយរំលំ ប៉ុល ពត <បានទេ នោះយើងអាច>អំពាវនាវ ហើយសុំឲ្យមានការជួយ<ពីវៀតណាម> ហើយក៏ដូចជាសុំឲ្យមានកម្លាំងពីបូព៌ារបស់ ចាន់ ចក្រី មកជួយដែរ។ នេះ តាអឿន ប្រាប់ខ្ញុំថាដូច្នេះដែរ។ ហើយ<នៅខាងដើមនេះបន្តិច ក្នុងចម្លើយរបស់លោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជាដដែលនោះ> លោកឆ្លើយថា វៀតណាមក៏បានចូលមកជួយដែរ រហូតដល់ផែនការនេះវាបែកការណ៍ទៅ។" តើវាត្រឹមត្រូវដែរឬទេ ដែលលោកបានឆ្លើយថាអ៊ីចឹង ថាក៏មានកម្លាំងវៀតណាមមកជួយដែរ ក៏ប៉ុន្តែអាផែនការហ្នឹងក៏វាបែកការណ៍ទៅ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមធ្វើការកត់សម្គាល់មួយ<ដើម្បីកំណត់ត្រាប្រតិចារឹក គឺថា មេធាវីការពារក្ដីមិនបាននិយាយ>ពាក្យ<>សំខាន់<ពីរពាក្យនៅក្នុង>ចម្លើយទី១ ដែលគាត់បានអាន។ <>សាក្សីបានប្រើពាក្យថា "ខ្ញុំស្មាន<>" ហើយមេធាវី<បានបន្ថែម>ពាក្យនេះ <ក្នុងការអានចម្លើយរបស់សាក្សី>។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំ បាទខ្ញុំសូមអានសម្រង់នេះទាំងស្រុងតែម្ដងលោកប្រធាន។ "សួរ៖ យោងទៅតាមការ<>រៀបចំនោះ តើលោកយល់ឃើញថា កម្លាំងទាំងអស់នេះ អាចយកជ័យជម្នះលើ ប៉ុល ពត បានទេ? ឆ្លើយ៖ ខ្ញុំគិតថា ឬខ្ញុំស្មានថា មិនស្រួលទេ។ <បើ>មិនអាចយកជ័យជម្នះលើ ប៉ុល ពត បានទេ <យើងអាចអំពាវនាវឲ្យ>វៀតណាមជួយ ក៏ដូចជាហៅឲ្យមានកម្លាំងជំនួយពី ចាន់ ចក្រី ពីបូព៌ាមកដែរ"។

[០៩:៤៨:១៣]

ដូច្នេះ ពាក្យអង់គ្លេសដែលថា "*អាយ ហ្គេស*" កន្លែងនេះ គឺខ្ញុំគិតថា <វានិយាយអំពីការ>មិនជាងាយក្នុងការយកជ័យជម្នះលើ ប៉ុល ពត ទេ។ <ដូច្នេះ ខ្ញុំគិតថា ការស្មាននេះ មិនមានអ្វីពាក់ព័ន្ធនឹងការផ្ដួលរំលំ ប៉ុល ពត និង>ការអំពាវនាវឲ្យមានជំនួយពី ចាន់ ចក្រី និងវៀតណាមទេ។ នេះ គឺជាការបកប្រែ គឺយ៉ាងដូច្នេះឯង។ ក៏ប៉ុន្តែមិនថ្វីទេលោក ប្រធាន ខ្ញុំសូមបន្តទៅមុខទៀតចុះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីថា <តើត្រឹមត្រូវទេ តើលោកបាននិយាយថា> "បើសិនណាជាមិនអាចយកជ័យជម្នះលើ ប៉ុល ពត បាន <យើងអាច>អំពាវនាវ<>ទៅដល់ប្រទេសវៀតណាម និង ស្នើសុំឲ្យមានកងទ័ពជំនួយពីខាង ចាន់ ចក្រី មកជួយ។ តើនេះគឺជាអ្វីដែល តាអឿន បានប្រាប់លោកមែនទេ?

**លោក ស៊្វិយ សៅ៖**

**ឆ៖** បាទ ពិតប្រាកដអ៊ីចឹងឯងបាទ។

**ស៖** បាទ ខ្ញុំដឹងថារឿងនេះកើតឡើងយូរណាស់មកហើយលោកសាក្សី ប៉ុន្តែលោកចាំទេថា តើគាត់និយាយយ៉ាងម៉េចខ្លះ? <តើ>គាត់<បាន>ប្រាប់លោក ហើយនិងប្រាប់អ្នកផ្សេងទៀតនៅកងពល

នោះ ថាតើត្រូវស្នើសុំជំនួយពីវៀតណាមយ៉ាងម៉េច ហើយតើ ចាន់ ចក្រី គាត់<គិតថា>ត្រូវធ្វើ<អ្វីខ្លះ>? លោកនៅចាំពាក្យសម្តីដែលលោក -- ដែលតាអឿន គាត់បាននិយាយនៅពេលនុ៎ងទេ?

**ឆ៖** មិនចាំទេ ភ្លេចអស់ បាត់ទៅហើយ។

[០៩:៤៩:៤៨]

**ស៖** នៅទំព័រដដែលលោក បាននិយាយច្បាស់លាស់ជាងនេះ ពាក់ព័ន្ធនឹងការជួយរបស់វៀត-ណាម ក្នុងការធ្វើរដ្ឋប្រហារវាយចូលទីក្រុងភ្នំពេញ ពេលនោះគេសួរថា "តើកង<ទ័ព>ទាំង១០០នាក់ហ្នឹង<អាចយកជ័យជម្នះលើ> ប៉ុល ពត <បាន>ទេ? ពេលនោះ លោកឆ្លើយថា បាទ<ពិតណាស់> ខ្ញុំគិតថាអ៊ីចឹង ដំបូងគេ<មានផែនការ>វាយ<>ពីខាងក្នុង។ <នៅពេល>ផែនការ<នោះបែកការណ៍> គឺគេ<មានផែនការអំពាវនាវ>សុំជំនួយពីយួនឲ្យជួយ" សូមបញ្ចប់ការដកស្រង់។ លោកចាំថាលោកបានឆ្លើយចម្លើយបែបនេះជូនមជ្ឈមណ្ឌលឯកសារកម្ពុជាទេ?

**ឆ៖** ឆ្លើយមែន។

**ស៖** ចុះ តាអឿន គាត់មានបានពន្យល់ថាតើគេធ្វើយ៉ាងម៉េចដើម្បីសុំជំនួយពីយួននោះ? តើៗតាអឿន ហ្នឹងគាត់មានគម្រោងធ្វើយ៉ាងម៉េចដែរ បើសិនជាផែនការបែកធ្លាយនោះ?

**ឆ៖** អានោះ ខ្ញុំក៏មិនដឹងដែរ ព្រោះខ្ញុំកូនទាហានដែរនោះ មិនដឹងដែរផែនការ។

**ស៖** ខ្ញុំយល់ហើយ។ ចុះ ចាន់ ចក្រី <និងកងកម្លាំងគាត់មកពីបូព៌ា គិតថា>ធ្វើយ៉ាងម៉េចដែរ? តាអឿន គាត់មានបាននិយាយប្រាប់លោកទេ<>ពេលនៅក្នុងប្រជុំសម្ងាត់ហ្នឹងថា ចាន់ ចក្រី ហ្នឹងភារកិច្ចគាត់មានអ្វីខ្លះដែរក្នុងផែនការនោះ?

**ឆ៖** អានោះ ខ្ញុំមិនដឹងដែរ។

[០៩:៥១:២៨]

**ស៖** បាទ ខ្ញុំនឹងព្យាយាមរំឭកការចងចាំរបស់លោកបន្ថែមទៀត។ លោកសាក្សី មានស្ត្រីមួយរូបគឺយុទ្ធនារីមកពីកងពល៣១០<> ដែលផ្តល់សក្ខីកម្មជូនមជ្ឈមណ្ឌលឯកសារកម្ពុជាផងដែរ ខ្ញុំមិនប្រាប់ឈ្មោះគាត់ទេ គាត់គឺលេខរហស្សនាមគាត់ 2-TCW-1030 <ក្នុងចម្លើយ>របស់គាត់គឺE3/7540 ខ្ញុំសូមរកមើល ERN សិន បាទជាភាសាអង់គ្លេស 00337712, ខ្មែរ00055077, បារាំង00364274។ បាទ យុទ្ធនារីរូបនេះ គាត់ឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់នូវចម្លើយរបស់គាត់ "សួរ៖ <តើវាអាច>ផ្ទុះឡើង<ទេ>? <ឆ្លើយ៖ វាបានផ្ទុះឡើង>នៅឆ្នាំ៧៦ ហើយខ្ញុំភ្លេចខែបាត់ទៅហើយ។ <នៅ>ចុង៧៦

ហ្នឹង<យើងប្រុងនឹង>ផ្ទុះ<ទៅហើយ ប៉ុន្តែវាបានបែកការណ៍ទៅ។ កងពលពីររបស់ភូមិភាគឧត្តរបានត្រៀមរួចហើយពីខាងជើង>វត្តភ្នំ។ ខាងបូព៌ាទទួលបន្ទុកខាងត្បូង ភាគខាងត្បូង <និងបានត្រៀមខ្លួនដើម្បីវាយរួចហើយ ប៉ុន្តែវាបានបែកការណ៍ទៅ> ហើយ ឃួន ជាប្រធានភូមិភាគឧត្តរហ្នឹងត្រូវបានចាប់ខ្លួន" សូមបញ្ចប់ការដកស្រង់។ លោកសាក្សីយុទ្ធនារីមកពីកងពល៣១០រូបនេះ បានឆ្លើយថាកងពល<ចំនួនពីររបស់ភូមិភាគឧត្តរ>ហ្នឹងគឺ<បានត្រៀមខ្លួនរួចហើយនៅខាងជើង>វត្តភ្នំ។ <តើ>លោកចាំ<ថា> តាអឿន គាត់បាននិយាយ<បែបនេះ>នៅក្នុងកិច្ចប្រជុំសម្ងាត់ហ្នឹងទេ?

**ឆ៖** ខ្ញុំមិនចាំទេ ខ្ញុំភ្លេចអស់ទៅហើយ។

[០៩:៥៤:១១]

**ស៖** ចុះកម្លាំងបូព៌ា? លោកបាននិយាយអំពីឈ្មោះ ចក្រី និងកម្លាំងនៅកង -- នៅភូមិភាគបូព៌ាតើពួកគាត់ហ្នឹងត្រូវវាយប្រហារចូលទីក្រុងភ្នំពេញហ្នឹងពីភាគខាងត្បូងមកមែនទេ? គឺមុខព្រួញពីទិសនៅទិសខាងត្បូងមែនទេ?

**ឆ៖** បាទ ខាងត្បូងហ្នឹងឯងបាទ។

**ស៖** ដូច្នេះ កងពលទាំងពីរគឺ៣១០ និង៤៥០ហ្នឹងមានភារកិច្ចវាយចូលទីក្រុងភ្នំពេញពីខាងជើង ហើយកងកម្លាំងបូព៌ា គឺវាយចូលតាមមុខព្រួញខាងត្បូង។ ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ត្រូវហើយ។

**ស៖** ឥឡូវនេះ ខ្ញុំសូមត្រឡប់មកនិយាយម្តងទៀត អំពីសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន។ លោកបាននិយាយឈ្មោះគាត់នៅក្នុងចម្លើយរបស់លោក ហើយមានយុទ្ធជនកងពល៣១០ម្នាក់ទៀត ក៏និយាយអំពីសម្តេច ហ៊ុន សែន ដែរគឺឯកសារ E3/7583 ហើយខ្ញុំក៏មិនប្រាប់ឈ្មោះសាក្សីរូបនេះដែរ គឺ 2-TCW- (រហស្សនាមគាត់គឺ) 1033។ គាត់បានឆ្លើយដូចតទៅ ប្រហែលជាគាត់និយាយអំពីកិច្ចប្រជុំមួយទៀត មិនមែនកិច្ចប្រជុំដដែលទេ។ ខ្ញុំសូមដកស្រង់៖ "នេះជាការប្រជុំក្បត់ ពីព្រោះថាគេនឹងរៀបចំការបះបោរ វាជាកិច្ចប្រជុំ សេ.អ៊ី.អា។ នៅពេលនោះពួកគេរៀបចំផែនការវាយប្រហារកងកម្លាំង ប៉ុល ពត ប៉ុន្តែបរាជ័យទៅ ពីព្រោះថា តាអឿន ដែលនៅក្នុងក្រុមជាមួយនឹង ហ៊ុន សែន ហ្នឹងត្រូវបានគេចាប់ខ្លួន។ សាក្សីរូបនេះ គាត់បាននិយាយអំពីថា ហ៊ុន សែន នៅក្នុងក្រុមតែមួយជាមួយ តាអឿន។ តើលោកមាននឹកឃើញអ្វីឡើងវិញត្រង់ចំណុចនេះ?

**ឆ៖** ខ្ញុំនឹកមិនឃើញទេ ភ្លេចបាត់ហើយ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកព្រះរាជអាជ្ញា!

[០៩:៥៧:០៣]

**លោក ឌេល លីសាក់៖**

បាទ ខ្ញុំគ្រាន់តែសុំឲ្យមេធាវីការពារក្តីឲ្យលេខ ERNផង ដើម្បីឲ្យយើងអាចពិនិត្យមើលបាន។

**លោក វិចទ័រ កូប៉េះ៖**

បាទ សូមអភ័យទោសផង គឺទំព័រ៣២, អង់គ្លេស 00876559, ខ្មែរ 00053869, បារាំង 00407996។ លោកសាក្សី ដូចដែលខ្ញុំបានប្រាប់លោករួចមកហើយ មានយុទ្ធជនមកពីកងពល៣១០ ជាច្រើនដែលនិយាយអំពីរដ្ឋប្រហារផ្តួលរំលំ ប៉ុល ពត និងរបៀបនៃការអនុវត្តរដ្ឋប្រហារនេះ។ ឥឡូវនេះ ខ្ញុំសូមអានឲ្យលោកស្តាប់នូវសក្ខីកម្មរបស់បុគ្គលដែលខ្ញុំបានប្រាប់លើកមុននេះ គឺ សែម ហឿន គាត់បានផ្តល់សក្ខីកម្មនៅតុលាការនេះ នៅថ្ងៃទី២៣ មិថុនា ឆ្នាំ២០១៥ នៅពេលព្រឹក គាត់បាននិយាយដូចតទៅនៅម៉ោង ០៩:១១ នាទី។ "សួរ៖ តើគេមានចេតនាវាយយក រួមជាមួយនឹងការវាយយកពោធិ៍ចិនតុង និងស្ថានីយវិទ្យុហ្នឹង គឺដើម្បីផ្តួលរំលំកម្ពុជាប្រជាធិបតេយ្យមែនទេ? បាទ មែនហើយ គឺគេមានចេតនាកាន់កាប់<ស្ថានីយ>វិទ្យុ ហើយក្រោយមកគឺកាន់កាប់<ព្រលានយន្តហោះ>ពោធិ៍ចិនតុងដើម្បីកុំឲ្យមានកងកម្លាំងណាមកជួយចូលកម្ពុជាប្រជាធិបតេយ្យ។ សួរ៖ ខ្ញុំយល់ហើយ ក៏ប៉ុន្តែតើគេមានចេតនាផ្តួលរំលំរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬក៏ធ្វើរដ្ឋប្រហារដែរឬទេ? ចម្លើយ៖ បាទនេះគឺជាគោលដៅចុងក្រោយរបស់គេ គឺគេចង់ធ្វើរដ្ឋប្រហារហ្នឹងឯង។"

ឥឡូវនេះ ខ្ញុំចូលដល់ផ្នែកសំខាន់ ចុះមកក្រោមបន្តិចមកគឺនៅម៉ោង ០៩:១៣ នាទី។ គាត់ថា "ខ្ញុំសូមបំភ្លឺអំពីផែនការបះបោរ មានតា សោ ភឹម នៅបូព៌ា និងតា កុយ ធួន នៅឧត្តរ។ ពួកគេរៀបចំកម្លាំងដើម្បីវាយប្រយុទ្ធ<នៅសមរភូមិមុខ និងនៅសមរភូមិក្រោយ>។ កងកម្លាំង<មជ្ឈិមត្រូវបានគេត្រៀមសម្រាប់ខ្សែសមរភូមិមុខ ក្នុងផែនការ>វាយចូលទីក្រុងភ្នំពេញ។ <កងកម្លាំងតំបន់គឺសម្រាប់វាយប្រហារពីខាងក្រោយ នៅកម្រិតតំបន់។> នេះជាអ្វីដែលខ្ញុំដឹង។" សូមបញ្ចប់ការដកស្រង់។

[១០:០០:១៥]

សាក្សីដដែលនេះ នៅពេលដែលគាត់និយាយអំពីស្ថានីយវិទ្យុនោះគឺគាត់សំដៅទៅលើស្ថានីយវិទ្យុនៅស្ទឹងមានជ័យ។ នេះជាអ្វីដែលគាត់និយាយនៅម៉ោង ០៩:០៩នាទី។ លោកសាក្សី លោកខ្លួនឯងផ្ទាល់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

<នៅក្នុងចម្លើយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា> បាននិយាយយ៉ាងច្រើនអំពី សោ ភឹម។ តើលោកដឹងថា សោ ភឹម បានចូលរួមពាក់ព័ន្ធនៅក្នុងផែនការរដ្ឋប្រហារ ឬក៏បះបោរវាយយកទីក្រុងភ្នំពេញនៅចុងឆ្នាំ៧៦ ដើមឆ្នាំ៧៧ នេះដែរឬទេ?

**ឆ៖** ខ្ញុំមិនដឹងទេ រឿងនុះនោះ។

**ស៖** ឥឡូវនេះ ខ្ញុំសូមសួរលោកថា តើខ្លួនលោកផ្ទាល់នោះ លោកចាំអ្វីខ្លះពី សោ ភឹម? តើ សោ ភឹម នេះជាអ្នកណា?

**ឆ៖** ខ្ញុំមិនស្គាល់ទេ។

**ស៖** ខ្ញុំដឹងថាវាជាការលំបាកក្នុងតុលាការជាសាធារណៈដែលលោកត្រូវនិយាយអំពីបញ្ហានេះ។ ក៏ប៉ុន្តែនៅក្នុងចម្លើយរបស់លោកនេះ លោកបាននិយាយជាច្រើនអំពី សោ ភឹម។ អ៊ីចឹងខ្ញុំសួរលោកម្តងទៀត <តើ>លោក<ចាំទេ>ថា<> សោ ភឹម នេះ<ជានរណា>?

**ឆ៖** ថា ខ្ញុំភ្លេចបាត់ហើយរឿងនោះ។

[១០:០២:០៥]

**ស៖** លោកដឹងអំពីការបះបោរនៅភូមិភាគបូព៌ា ក្រោមការដឹកនាំរបស់ សោ ភឹម ទេ?

**ឆ៖** ខ្ញុំមិនដឹងដែរ។

**ស៖** ឥឡូវនេះ ខ្ញុំសូមត្រឡប់មកនិយាយអំពីសក្ខីកម្មរបស់លោកជូនមជ្ឈមណ្ឌលឯកសារកម្ពុជា។ ពេលមួយនោះ លោកបាននិយាយថា៖ "ខ្ញុំត្រូវបានគេបញ្ជូនទៅកងចល័ត<នៅខាងត្បូងជ្រាំ> ជាមួយតា សោ ភឹម។" ហើយលោកបាននិយាយអំពីមន្ទីរពេទ្យមួយ។ លោកថា៖ "អ៊ីចឹងលោកត្រូវបានគេបញ្ជូនទៅឲ្យទៅនៅជាមួយ សោ ភឹម មែនទេ? ឆ្លើយ៖ បាទ គឺគេឲ្យខ្ញុំទៅ<>នៅការពារ<កងចល័តនៅ>ខាងសមរភូមិក្រោយ។ សួរ៖ ការពារកងចល័តមែនទេ? <ឆ្លើយ>៖ គេខ្លាច<>ក្រុមកងចល័តហ្នឹងរត់<ចូលព្រៃ> ហើយមានការចាប់ខ្លួន<ដោយកងកម្លាំងបូព៌ា ដែលញុះញង់បះបោរហើយរត់ចូលព្រៃមុននោះ>។ <សួរ៖ លោកថា កងកម្លាំងនិរតីញុះញង់បះបោរមែនទេ? លោកឆ្លើយថា បាទ។ ហើយគេសួរបន្តទៀត> តើខាងភូមិភាគបូព៌ាហ្នឹង គេញុះញុងឲ្យមានការបះបោរយ៉ាងម៉េច? លោកឆ្លើយថា គេ<បានរត់ចូលទៅ>ក្នុងព្រៃ <ហើយបានចាប់ផ្តើមវាយប្រយុទ្ធ>ប្រឆាំងនឹង ប៉ុល ពត។ <សោ ភឹម ជាអ្នកដឹកនាំកងកម្លាំងបះបោរ។> ហើយបន្ទាប់មក<កងកម្លាំងរបស់> ប៉ុល ពត បានកម្ទេចកម្លាំង<របស់ សោ ភឹម>។ ហើយមានអ្នកខ្លះទៅ រត់ពួននៅក្នុងព្រៃ។ សួរ៖ ចុះ សោ ភឹម យ៉ាង

ម៉េចដែរ? <ឆ្លើយ៖> សោ ភឹម គាត់បាញ់សម្លាប់ខ្លួនឯង។ សួរ៖ តើលោកឃើញសាកសពគាត់ទេ? ឆ្លើយ៖ ខ្ញុំអត់ឃើញទេ។ ប៉ុន្តែអ្នកផ្សេងឃើញសពរបស់គាត់ គេដាក់ទឹកកក ហើយគេដឹកក្នុងឡាន។" លោកសាក្សី លោកនៅចាំឆ្លើយដែលលោកបានឆ្លើយនេះទេ ពាក់ព័ន្ធនឹង សោ ភឹម?

**ធ៖** ចាំបាននេះដែរ ប៉ុនខ្លាចឆ្លើយវាទៅមិនរួច។ ភ្លេចដុបៗបាត់ហើយ។

**ស៖** ឥឡូវនេះ ខ្ញុំសួរលោកអ៊ីចេះវិញ។ <តើនេះជា>អ្វីដែល<លោកបានឆ្លើយជាមួយ> មជ្ឈមណ្ឌលឯកសារកម្ពុជា<មែនទេ? តើអ្វីដែលខ្ញុំបានអានពីចម្លើយរបស់លោកនេះ>ជាការត្រឹមត្រូវទេ? <តើវាជាការចងចាំបានត្រឹមត្រូវអំពី>ហេតុការណ៍ដែលពិតជាបានកើតឡើងនៅឆ្នាំ៧៨ នៅពេលនុ៎ងទេ?

[១០:០៤:៦៥]

**ធ៖** ត្រឹមត្រូវហើយ បាទ។

**ស៖** លោកដែលជួប សោ ភឹម ផ្ទាល់ទេ? លោកធ្លាប់ឃើញគាត់ដោយផ្ទាល់ភ្នែកទេ?

**ធ៖** ខ្ញុំមិនដែលជួបផង។

**ស៖** លោកចាំទេថា កងកម្លាំងរបស់ សោ ភឹម ហ្នឹងវាយប្រយុទ្ធគ្នាជាមួយនឹងកងកម្លាំង ប៉ុល ពត ហ្នឹងនៅកន្លែងណាដែរ? ហើយនៅពេលណា?

**ធ៖** អ៊ូ! ខ្ញុំមិនចាំទេ ភ្លេចបាត់ហើយ។

**ស៖** ចុះម៉េចក៏លោកដឹងថា សោ ភឹម ហ្នឹងបាញ់សម្លាប់ខ្លួនឯង?

**ធ៖** កងទ័ពគេនិយាយនៅមុខហ្នឹងឯង។

**ស៖** លោកចាំទេ ពេលដែលលោកឮរឿងរ៉ាវថា សោ ភឹម គាត់បាញ់សម្លាប់ខ្លួនឯងហ្នឹងលោកនៅកន្លែងណាដែរ?

**ធ៖** នៅកណ្ដាលជ្រំ។

[១០:០៦:២៥]

**ស៖** នៅក្នុងចម្លើយរបស់លោកជូនមជ្ឈមណ្ឌលឯកសារកម្ពុជា អង់គ្លេស 00324184, ខ្មែរ 00087837, បារាំង 00324226 លោកបានឆ្លើយដូចតទៅ៖ "តាំងពី សោ ភឹម, <បានធ្វើយុទ្ធនាការបះបោរ> -- សំណួរទេតាមពិត "តាំងពី សោ ភឹម, <បានធ្វើយុទ្ធនាការ>បះបោរមកនុ៎ង តើពួកប្រជាជន<នៅបូព៌ាត្រូវបានគេចាប់ដាក់គុក> ឬក៏<រស់នៅដូចធម្មតាទេ>? ឆ្លើយ៖ កម្លាំងហ្នឹងគេមិនប៉ះពាល់

ដល់ប្រជាជនធម្មតាទេ”។ សូមបញ្ចប់ការដកស្រង់។ លោកចាំចម្លើយបែបហ្នឹងទេ លោកឆ្លើយថា កម្លាំងប៉ុល ពត ហ្នឹងគេអត់ប៉ះពាល់ ឬក៏ធ្វើអីចំពោះប្រជាជនសាមញ្ញទេ?

**ឆ៖** បាទ ខ្ញុំឆ្លើយអ៊ីចុះឯងមែនបាទ ប្រជាជនសុទ្ធសាធហ្នឹង ហើយមានណាទ័ពធ្វើអី អត់។

**ស៖** តើលោកដឹងព័ត៌មាននេះពីណា? លោកមានប្រភពអីដែលធ្វើឲ្យលោកប៉ានសន្និដ្ឋានបែបហ្នឹង?

**ឆ៖** អង្កាល់នោះ បើទ័ពមិននៅ ធ្វើម៉េចប្រជាជនផង។

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយពីចំណុចនេះនៅពេលក្រោយ ប៉ុន្តែឥឡូវនេះ ខ្ញុំងាកមកសំណួរដើមរបស់ខ្ញុំវិញ។ ឥឡូវនេះលោកចាំអំពី សោ ភឹម លោក<ចាំថាលោកធ្លាប់>នៅភូមិភាគបូព៌ា។ អ៊ីចឹងពេលដែល សែម ហឿន គាត់បាននិយាយនៅក្នុងសវនាការនេះថា រដ្ឋប្រហារនៅដើមឆ្នាំ -- ចុងឆ្នាំ៧៦ និងដើមឆ្នាំ៧៧ ហ្នឹងគឺជាការរួមកម្លាំងគ្នារវាងបូព៌ានិងឧត្តរ ហើយ សោ ភឹម ក៏បានចូលរួមនៅក្នុងការប៉ុនប៉ងធ្វើរដ្ឋប្រហារនេះជាមួយនឹង កុយ ធួន នេះ។ គាត់និយាយអ៊ីចឹងតើត្រឹមត្រូវទេ?

[១០:០៨:៥៧]

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំគិតថាប្រហែលជាពេលវេលាសមស្របនឹងសម្រាកហើយ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។

នៅពេលនេះ អង្គជំនុំជម្រះប្រកាស២០នាទី ចាប់ពីពេលនេះតទៅ។

*(សវនាការសម្រាកពីម៉ោង ១០:១០ នាទី ដល់ម៉ោង ១០:៣០ នាទី)*

[១០:២៩:៤៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាទៅលោកព្រះរាជអាជ្ញាមានសំណួរ។

**លោក វ៉ិចទ័រ កូប៉េ៖**

<ទេ អត់ទេលោកប្រធាន ខ្ញុំនៅសួរមិនទាន់ចប់ផង។>

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៣១:២៤]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

មានភាពមិនច្បាស់លាស់។ អ៊ីចឹង ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់លាស់បន្តិច ពីសំណាក់អង្គជំនុំជម្រះ។ អ្វីដែលលោកលើកឡើងព្រឹកមិញនេះ លោកមេធាវី គឺថាលោក<ប្រើប្រាស់វគ្គទី១ ហើយលោក>សហការជាមួយក្រុមមេធាវីការពារក្ដី ខៀវ សំផន ដែល<គាត់រីករាយនឹងផ្ដល់>ពេលវេលាភាគច្រើននៃវគ្គទី២នេះ<ទៅលោក>។ ដូច្នេះ អ៊ីចឹង នៅពេលដែលលោកបញ្ចប់ការតាំងសំណួរដោយប្រើប្រាស់ពេលវេលាដែលលោកបានលើកឡើង យើងនឹងប្រគល់នាទីនេះ ទៅជូនខាងភាគីសហព្រះរាជអាជ្ញា <និងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ហើយអ្វីដែលនៅសល់ នឹងប្រគល់ឲ្យក្រុមមេធាវីលោកខៀវ សំផន>។ អ៊ីចឹង អង្គជំនុំជម្រះយល់យ៉ាងដូច្នេះ ត្រឹមត្រូវទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ត្រឹមត្រូវហើយ លោកស្រីចៅក្រម។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំនៅសល់ពេលត្រូវសួរលោក សែសិប --ប្រហែលជា ៤០នាទីទៀត។ បាទ មុនពេលឈប់សម្រាកមុននេះ យើងបាននិយាយគ្នាពីឈ្មោះ សោ ភឹម។ ខ្ញុំបានជួយរំឭកដល់ការចងចាំរបស់លោកខ្លះៗដែរ ហើយមុនពេលឈប់សម្រាក ក៏ខ្ញុំបានអានសម្រង់មួយដែលជាសក្ខីកម្មរបស់ សែម ហឿន និយាយពាក់ព័ន្ធរវាង សោ ភឹម ទៅនឹង កុយ ធួន ដែលនិយាយអំពីគោលបំណងនៃការធ្វើរដ្ឋប្រហារ។ ហើយពីខាងដើមនេះ ពេលដែលខ្ញុំរំឭកពីឈ្មោះ កុយ ធួន លោកនឹកមិនឃើញទេ។ ក៏ប៉ុន្តែខ្ញុំសូមលើកយកសក្ខីកម្មរបស់សាក្សីផ្សេងមួយទៀត ក្រែងវារំឭកដល់ការចងចាំរបស់លោកផងដែរ។

លោកប្រធាន ខ្ញុំយោងទៅលើឯកសារ E3/5686 ដែលជាសក្ខីកម្មឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជាពីសាក្សីម្នាក់គឺ 2-TCW-1032 បាទ ដែលជាយុទ្ធជនមកពី<កងពល>តូចលេខ១។ ERN អង់គ្លេស 00874668, ខ្មែរ <00020553>, បារាំង 00904123។ “សួរ៖ វាបានកើតឡើងនៅក្នុងរបបនោះ ខ្ញុំមិនដឹងថា ពេលណាឲ្យច្បាស់លាស់ទេ។ តែខ្ញុំបានឮថា តាអឿន ចាប់ផ្ដើមធ្វើការបះបោរ។” ហើយយុទ្ធជនរូប<នេះ>បានឆ្លើយថា “អូ៎! គាត់សហការគ្នាជាមួយនឹងបក្សពួក ធុច។ សួរ៖ ថាតើធុចហ្នឹងទទួលខុសត្រូវខាងផ្នែកអ្វីដែរ? ឆ្លើយ៖ ធុច ហ្នឹង ទទួលខុសត្រូវខាងក្រសួង។ សួរ៖ តើតាអឿន

ហើយ ធុច ហ្នឹង រៀបចំ មានផែនការរៀបចំធ្វើអ្វី? សាក្សីឆ្លើយថា៖ ពួកគេរៀបចំធ្វើការបះបោរ។ ខ្ញុំឃើញពួកគេមានអាវុធធុនតូច ធុនធំ ហើយក្រោយមក បក្ខពួក ពួកទាំងអស់នេះក៏ត្រូវបានចាប់ខ្លួនទាំងនៅក្នុងវរសេនាតូច និង<វរសេនាធំ>។" ធុច ទទួលខុសត្រូវនៅខាងក្រសួង។ តើសម្ដីរបស់សាក្សីម្នាក់នេះ ជួយរំឭកដល់ការចងចាំរបស់លោកដែរទេ លោកសាក្សី?

[១០:៣៥:០៤]

**លោក ស៊្វីយ សៅ៖**

**ឆ៖** ខ្ញុំចាំមិនបានដែរ។

**ស៖** មិនថ្វីទេលោកសាក្សី ខ្ញុំព្យាយាមតាមរបៀបផ្សេងម្ដងទៀត។

ឥឡូវនេះ ខ្ញុំយោងទៅលើឯកសារ E3/509។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធានឯកសារ E3/509 ជាកំណត់ហេតុស្ដាប់ចម្លើយនៃយុទ្ធជនកងពលមកពីកងពល ៣១០ អង់គ្លេស 00282217, ខ្មែរ 00270159, បារាំង 00285597។ យុទ្ធជនរូបនេះបាននិយាយអំពី <>រដ្ឋប្រហារ បាននិយាយអំពីសកម្មភាពរបស់យុទ្ធជនមកពី<វរសេនាតូចលេខ៣០៦> ដែលពួកគេបើកការប្រយុទ្ធនៅម៉ោងបីទៀបភ្លឺ ដើម្បីដណ្ដើមយកវិទ្យុផ្សាយសំឡេងនៅទីក្រុងភ្នំពេញ ហើយសាក្សីរូបនេះក៏បានផ្ដល់សក្ខីកម្មលម្អិតផងដែរ។ ហើយបន្ទាប់មក<គាត់>និយាយថា "នៅយប់នោះ ភ្លាមមកតាអឿន, តាស៊ីនួន អតីតមេបញ្ជាការកងវរសេនាតូច<៣០៦> ហើយនិង <អឿន> ដែល<នៅ>ខាងផ្នែកពាណិជ្ជកម្មនាពេលនោះ"។ លោកសាក្សី តើលោកដឹងថា ឈ្មោះ អឿន <ក្នុងអំឡុងពេល>រៀបចំធ្វើរដ្ឋប្រហារ<នេះ បាន>សហការជាមួយអ្នកដែលមកពីក្រសួងពាណិជ្ជកម្ម <តើលោកដឹង>ទេ?

**ឆ៖** ខ្ញុំនឹកមិនឃើញឯណា។

[១០:៣៦:៥៧]

**ស៖** ចុះខ្លួនលោកផ្ទាល់ មាននឹកឃើញអ្នកណាម្នាក់ធ្វើការនៅក្រសួងពាណិជ្ជកម្មដែលពីមុនមកនោះ គាត់គឺជាមនុស្សដែលមកពីភូមិភាគឧត្ដរចាស់។ លោកនឹកឃើញទេ?

**ឆ៖** នឹកមិនឃើញទេ។

**ស៖** មិនថ្វីទេ អ៊ីចឹងខ្ញុំទុកឈ្មោះ កុយ ធួន នេះចោលមួយអន្លើសិនចុះ។ ឥឡូវខ្ញុំសូមចូលទៅនិយាយអំពីតួនាទីជាក់លាក់របស់លោកផ្ទាល់។ លោកនិយាយថា លោកជាអ្នកដឹកអាវុធ ដែលត្រូវយក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មកចូល ដឹកចូលមកទីក្រុងភ្នំពេញ ដើម្បីប្រើប្រាស់សម្រាប់ធ្វើការវាយប្រហារនេះ។ សែម ហឿន ក៏បានផ្ដល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះរួចមកហើយ ថាគាត់ហ្នឹងក៏ជាអ្នកដឹកជញ្ជូនអាវុធ<ទៅ>កំពង់ចាម <ទៅឲ្យមនុស្សម្នាក់ឈ្មោះ តុល> ហើយគាត់នេះបានៗពន្យល់លម្អិតណាស់អំពីប្រភេទអាវុធផ្សេងៗដែលត្រូវយកមកប្រើប្រាស់ ដើម្បីធ្វើការវាយប្រយុទ្ធនេះ។

[១០:៣៨:១៨]

លោកប្រធាន នេះគឺសក្ខីកម្មរបស់គាត់នៅថ្ងៃទី២២ មិថុនា ឆ្នាំ២០១៥ នៅប្រហែលជាម៉ោង ១៥:៣៦ “សួរ៖ តើអាវុធប្រភេទណា ដែលលោកដឹក<ទៅ>កំពង់ចាមមក? ឆ្លើយ៖ គឺថាមានអាវុធផ្សេងៗគ្នា ដូចជាមានអឹម៧៩ អាវុធអា.កា”។ សំណួររបស់ខ្ញុំ សួរទៅលោកថាអ៊ីចេះ លោកនឹកឃើញទេ អាវុធ ដែលលោកដឹកជញ្ជូន<>ហ្នឹងមានតាំងពីអឹម៧៩ មានប្រភេទអាវុធអា.កា និងប្រភេទអាវុធផ្សេងៗទៀតដែរឬទេ?

**ឆ៖** អាវុធនោះ ខ្ញុំកាន់ជាប់ ព្រោះខ្ញុំ អា.ការបស់ខ្ញុំ មានបាននេះហើយ។ ខ្ញុំបំពាក់កាំភ្លើងតាំងពីដើមដែរ។

**ស៖** ខ្ញុំយល់ហើយ ក៏ប៉ុន្តែលោកបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជាថា លោកដឹកអាវុធ <ពីរ>ឡានពេញ<> ដើម្បីធ្វើការវាយប្រយុទ្ធនៅទីក្រុងភ្នំពេញ។ នៅក្នុងឡានកាមីញ៉ុង ដែលលោកដឹកអាវុធពេញ<នោះ> មានអាវុធអីខ្លះដែរ មានអា.កា <មានអឹម៧៩ទេ>?

**ឆ៖** មានអាវុធ ខូសេត ការ៉ូណូប ហើយនិង ដេ.កា។

[១០:៤០:00]

**ស៖** សូមឲ្យអ្នកបកប្រែ សូមបកម្ដងទៀត ខ្ញុំស្ដាប់អត់បានច្បាស់ចម្លើយសាក្សីអម្បាញ់មិញ។ បើដូច្នេះខ្ញុំសូមសួរម្ដងទៀត ដោយសារស្ដាប់ការបកប្រែជាភាសាអង់គ្លេសមិនបានច្បាស់លោកសាក្សី។ លោកសាក្សី នៅក្នុងរថយន្ត -- ឡានទាំងពីរនេះ ដែលលោកដឹកអាវុធពីរឡានពេញៗនេះ មានប្រភេទអាវុធអ្វីខ្លះដែរ?

**ឆ៖** ខូសេត, ការ៉ូណូប។

**ស៖** ខ្ញុំនៅតែមិនច្បាស់ មិនដឹងអាវុធស្អីទេ លោកថាអម្បាញ់មិញនេះ។ បាទ ឥឡូវខ្ញុំសាកល្បងសួរតាមរបៀបផ្សេងក្រែងវាអាចជួយដល់លោកបានខ្លះ។ លោកសាក្សីនៅក្នុងចម្លើយរបស់លោកផ្ទាល់ លោកបាននិយាយអំពីអាវុធនិងគ្រាប់កាំភ្លើង។ អង់គ្លេស 00324171, ខ្មែរ <00087821>, បារាំង

<00324209>។ លោកនិយាយអំពីអាវុធ គ្រាប់រំសេវមកពីប្រទេសចិន ដែល អឿន ត្រូវយកមកប្រើប្រាស់ក្នុងការបះបោរនេះ តើលោកពិតជាបាននិយាយដូច្នេះមែនទេថា អាវុធដែលយកមកហ្នឹង គឺជាអាវុធផលិតនៅប្រទេសចិន?

[១០:៤១:៥២]

**ឆ៖** អាហ្នឹងនិយាយមែនអ៊ីចឹងឯង ប៉ុន្តែខ្ញុំវាភ្លេចភ្លាំងអស់ហើយ។

**ស៖** ហើយអាវុធដែលលោកដឹកតាមឡានកាមីញ៉ុងទាំងពីរឡាននេះ គឺជាអាវុធដែលមក ផលិតនៅប្រទេសចិន ឬក៏អាវុធ<ប្រភេទ>ផ្សេង<>?

**ឆ៖** អានុ៎ង ខ្ញុំក៏មិនដឹងដែរ មិនដឹកមកពីត្រង់ណាមក។

**ស៖** តើលោកនៅនឹកឃើញទេថា នៅក្នុងឡានកាមីញ៉ុងទាំងពីរនេះ អាវុធសរុបទាំងអស់ហ្នឹងមានចំនួនប៉ុន្មានដើមដែរ?

**ឆ៖** ខ្ញុំក៏វាមិនដឹងដែរ អារឿងកាំភ្លើងហ្នឹង មានប៉ុន្មានដើមៗ ខ្ញុំក៏ភ្លេចអស់បាត់ទៅដែរ។

**ស៖** ឥឡូវ ខ្ញុំសួរតាមរបៀបផ្សេងទៅចុះ។ តាមរយៈសក្ខីកម្មរបស់លោកក៏ដូចជាសក្ខីកម្មរបស់អ្នកដទៃផងដែរ លោកបាននិយាយអំពីផែនការធ្វើរដ្ឋប្រហារ សូមដកស្រង់ "ត្រូវបានបែកការណ៍" បញ្ចប់ការដកស្រង់។ តើលោកដឹងទេថា ហេតុអីបានជាផែនការរដ្ឋប្រហារហ្នឹងវាបែកការណ៍? ហើយ<តើ>លោកដឹង<មូលហេតុទេ>ថា <ហេតុអ្វីបានជា>ផែនការរបស់ អឿន និងរបស់មេបញ្ជាការដទៃទៀតហ្នឹង គឺថាអត់បានទទួលជោគជ័យ<>?

[១០:៤៣:៣៧]

**ឆ៖** ដឹងទាល់តែគេចាប់គាត់បានដឹងថា គាត់មានផែនការវាយប្រហារ។

**ស៖** ខ្ញុំយល់ហើយ គឺថាគាត់ត្រូវបានគេចាប់ខ្លួនជាមួយនឹងមេដឹកនាំដទៃទៀត ក៏ប៉ុន្តែធ្វើម៉េចបានជា ប៉ុល ពត ក៏ដូចជាមេដឹកនាំដទៃទៀតនោះ ដឹងអំពីផែនការនេះ ហើយអាចទប់ស្កាត់មិនឲ្យរដ្ឋប្រហារនេះកើតឡើងបាន? លោកមានព្ញត៌មាន ឮដំណឹងពីខាងណាដែរទេ?

**ឆ៖** ខ្ញុំវាមិនដែលឮទេ។

**ស៖** គឺថាលោកកំពុងតែឆ្លើយថា ផែនការហ្នឹង គឺថាមិនអនុវត្តមិនបានជោគជ័យ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងឯង។

**ស៖** ឥឡូវខ្ញុំចូលទៅសួរលោកអំពីព្រឹត្តិការណ៍ក្រោយៗមកទៀត អ្វីដែលកើតឡើងក្រោយៗពីផែនការរដ្ឋប្រហារ។ លោកបានឆ្លើយថា យុទ្ធជនធម្មតាហ្នឹង គេអត់បានចាប់ខ្លួនទេ គេចាប់ខ្លួនតែមេដឹកនាំ តែមេបញ្ជាការទេ។ តើវាពិតជាអ៊ីចឹងមែនទេដែលលោកបានឆ្លើយថាយុទ្ធជនធម្មតាហ្នឹងគឺគេអត់ចាប់ខ្លួនទេ គេចាប់តែមេៗទេ ហើយធ្វើម៉េចបានជាលោកដឹងយ៉ាងដូច្នេះ?

**ឆ៖** បាទ គេអត់ចាប់មែននោះ នៅទាំងអស់យុទ្ធជន។

[១០:៤៥:១២]

**ស៖** បាទ យើងដឹងហើយថាខ្លួនលោកផ្ទាល់ហ្នឹងមិនត្រូវបានគេចាប់ខ្លួនទេ។ ចុះចំពោះយុទ្ធជនដទៃទៀតនោះ ម៉េចបានលោកដឹងថាគេមិនចាប់ខ្លួន?

**ឆ៖** ព្រោះអង្គភាពខ្ញុំ វាមិនឃើញមានចាប់នោះឯង យុទ្ធជននៅ។

**ស៖** ក្រោយពេល អឿន ត្រូវបានចាប់ខ្លួន តើមានអ្វីកើតឡើងមកទៀត? តើលោកនិងយុទ្ធជនដទៃទៀតត្រូវបានគេបញ្ជូនទៅណាដែរ?

**ឆ៖** បញ្ជូនទៅកប់ស្រូវធ្វើស្រែហ្នឹងណា។

**ស៖** តើលោកដឹងថាកងទ័ពកងពល៣១០ដទៃទៀតត្រូវបានស្នើសុំឲ្យទៅធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំងដែរឬទេ?

**ឆ៖** អានោះ ខ្ញុំមិនដឹងដែរអារឿងខាងនោះឯង។

**ស៖** តើលោកដឹងថាយុទ្ធជនមកពីកងពល៣១០ត្រូវបានគេបញ្ជូនទៅឲ្យធ្វើស្រែនៅឯព្រៃសដែរឬទេ?

**ឆ៖** អានោះ ខ្ញុំមិនដឹងដែរ។

[១០:៤៧:០៦]

**ស៖** បាទ ខ្ញុំសូមយកឯកសារមួយយកមកសួរលោក ព្រោះថាខ្លួនលោកផ្ទាល់មិនបានដឹងអំពីរឿងនេះទេ។ នេះគឺឯកសារ E3/849 លោកប្រធាន។ នេះជាស្ថិតិរួមរបស់កងទ័ពបដិវត្តន៍កម្ពុជាដែលចេញពីអគ្គសេនាធិការ កាលបរិច្ឆេទគឺថ្ងៃទី០៧ មេសា ១៩៧៧ ERN ជាភាសាអង់គ្លេស 00183956, បារាំង 00334995, ខ្មែរ 00052319។ លោកសាក្សី បាទ <កងពល៣១០ ក៏មាននិយាយនៅក្នុង> ឯកសារនេះ<ដែរ វា>ជាស្ថិតិរួមដែលចេញដោយ អគ្គសេនាធិការដែលគឺនៅថ្ងៃទី០៧ ខែមេសា ១៩៧៧។ បាទ គិតទៅ គឺឯកសារនេះចេញក្រោយពេល អឿន ត្រូវបានគេចាប់ខ្លួនហើយ<ប្រហែល

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

មួយខែកន្លះ> ដែលថាកងពល៣១០ហ្នឹងមានកងទ័ពទាំងអស់៦.០៩៦នាក់ ហើយ<ឯកសារនេះសរសេរថា "រួមទាំងកងកម្លាំង១.១២៧>នាក់<>នៅកំពង់ឆ្នាំង"។ តើលោកនៅនឹកឃើញទេថា ពីរបីខែក្រោយពេលចាប់ខ្លួន អឿន រួចមក កងទ័ពកងពល៣១០ប្រហែលជាមួយភាគប្រាំមួយហ្នឹងត្រូវបានបញ្ជូនទៅឲ្យធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង។ តើលោកដឹងឬទេ?

**ឆ៖** អានោះ ខ្ញុំមិនដឹងដែរ។

**ស៖** តើលោកនៅនឹកឃើញទេ ថាក្រោយពេល តាអឿន ត្រូវបានគេចាប់ខ្លួនទៅ មានចម្លើយសារភាពមួយចេញពី អឿន ផ្ទាល់ ក៏ដូចពី<អ្នកផ្សេងទៀតនៃ>កងទ័ព៣១០ <ត្រូវបានគេចាក់ផ្សាយសំឡេងនៅពេល>ប្រជុំ<>យុទ្ធជនកងពល៣១០<>?

[១០:៥០:០០]

**ឆ៖** ខ្ញុំមិនដឹងទេកាលនោះ។

**ស៖** សំណួរពីរបីចុងក្រោយទៅលើចំណុចនេះ លោកនិយាយថាយុទ្ធជនទាំងអស់មិនត្រូវបានគេចាប់ខ្លួនទេ គឺគេចាប់ខ្លួនតែមេៗទេ។ តើធ្វើម៉េចបានជាលោក ហេតុអីបានជាលោកដឹងថា មេៗត្រូវបានគេចាប់ខ្លួន? <ហេតុអ្វីបានជាលោកផ្តល់ចម្លើយបែបនេះទៅមជ្ឈមណ្ឌលឯកសារកម្ពុជា?> បើមុននោះខ្ញុំសួរ លោកបានឆ្លើយអំពីយុទ្ធជនធម្មតា ថាមិនត្រូវបានគេចាប់ខ្លួន។ ប៉ុន្តែ<ពេលនេះខ្ញុំនិយាយ>តែមេៗ <>ធ្វើម៉េចបានលោកដឹង<ថាមានតែមេៗទេ ដែលត្រូវបានគេចាប់ខ្លួន>?

**ឆ៖** ខ្ញុំដឹង បើឃើញនៅទាំងអស់ចុះហើយៗ។

**ស៖** ចុះលោកដឹងថាមេៗប៉ុន្មាននាក់ដែរ ដែលត្រូវបានគេចាប់ខ្លួន?

**ឆ៖** ខ្ញុំក៏មិនដឹងដែរ វាយុទ្ធជនហ្នឹងគេដែរ មិនដឹងគេចាប់ប៉ុន្មានៗ បើមិនបានគិតដែរ។

**ស៖** បាទ នេះគឺជាសំណួរចុងក្រោយរបស់ខ្ញុំ។ គឺវា<មិន>ពាក់ព័ន្ធទៅនឹងសក្ខីកម្ម<ពីខាងដើម>របស់លោក<ទេ។ នៅ>ទំព័រចុងក្រោយនៃសក្ខីកម្មរបស់លោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា E3/7535, ERN ជាភាសាអង់គ្លេស 00324190, ខ្មែរ 00087845, បារាំង 00324233។ លោកបានឆ្លើយដូចតទៅ គេបានសួរលោកអំពីការជំនុំជម្រះនៅអង្គជំនុំជម្រះវិសាមញ្ញ។ <គេសួរ>លោកថា៖ "<តើលោកគិតថា>ការជំនុំជម្រះនឹងផ្តល់<>ប្រយោជន៍ដល់រូបលោក និងប្រជាជនកម្ពុជាទាំងមូល<ទេ? ហើយបន្ទាប់មកលោកនិយាយថា>៖ <ការជំនុំជម្រះនឹង>ផ្តល់ប្រយោជន៍ដល់ប្រជាជនទាំងមូល<ឬ>? <ហើយបន្ទាប់មកគេសួរថា យ៉ាងម៉េច? ហើយលោកនិយាយ ខ្ញុំ>សូមដកស្រង់

ចម្លើយលោក៖ “ខ្ញុំមាន -- ខ្ញុំចង់និយាយថា <មានតែ>បក្ខពួក ហ៊ុន សែន <ទេ ដែល>បានប្រយោជន៍អំពីការបាត់បង់<ទ្រព្យសម្បត្តិ>នៅក្នុងរបបប៉ុលពតនេះ”។ សួរថាតើលោកចង់មានន័យដូចម្ដេចនេះចម្លើយដែលលោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជានេះ?

[១០:៥៣:១១]

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំយល់ឃើញថា សំណួរនេះមិនពាក់ព័ន្ធទៅនឹងវិសាលភាពនៃការជំនុំជម្រះនៅវគ្គនេះទេ។ <ទស្សនៈរបស់សាក្សីអំពី>ប្រយោជន៍<នៃការជំនុំជម្រះ ឬ>រដ្ឋាភិបាលសព្វថ្ងៃនេះ <គឺ>មិនពាក់ព័ន្ធទេ។

**លោក វ៉ិចទ័រ កូប៉េះ៖**

នេះគឺ<>ជាការស្មាន<ទៅលើមូលហេតុសម្រាប់ចម្លើយនេះ ខ្ញុំមិនដឹង>ទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមលោកពន្យល់ផងថា តើវាមានប្រយោជន៍យ៉ាងម៉េចរឿងនេះ?

**លោក វ៉ិចទ័រ កូប៉េះ៖**

អ៊ីចឹងខ្ញុំសូមរៀបសំណួរឡើងវិញ។ ឥឡូវបំភ្លេចចោលចុះរឿងមុនៗ។ លោកសាក្សី តើលោកចង់និយាយថាម៉េចនៀកកន្លែងនេះ ថាមានតែបក្ខពួក ហ៊ុន សែន ដែលៗមានប្រយោជន៍ទទួលបានទ្រព្យរបស់ដែលបាត់បង់ពីរបបប៉ុលពត? <តើលោកបានន័យថាម៉េច ពេលដែលលោកនិយាយបែបនេះ?>

[១០:៥៤:០៦]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ក៏ប៉ុន្តែ<សំណួរគឺសួរថា ហេតុអីបានជាសំណួរនេះពាក់ព័ន្ធទៅនឹងការជំនុំជម្រះនេះ? ហើយយើងកំពុងតែរង់ចាំស្ដាប់ការ>ពន្យល់<របស់លោក>អំពី<ភាពពាក់ព័ន្ធរបស់>សំណួរ<>នេះ <ព្រោះថាវាមានការជំទាស់។>

**លោក វ៉ិចទ័រ កូប៉េះ៖**

ខ្ញុំមិនច្បាស់ដែរ។ ពីព្រោះ<ខ្ញុំមិនដឹងថាហេតុអ្វីបានជា>សាក្សីគាត់<>និយាយ<>ដូច្នេះ។ អ៊ីចឹង<>ខ្ញុំ<មិនដឹងទេ។ បើសិនជា>គាត់ចង់និយាយថា <>អ្វីដែលកើតឡើងពីចន្លោះពី ៧៥ ទៅ ៧៩ ឬក៏<គាត់និយាយអំពីបញ្ហាបណ្ដោះអាសន្ន ខ្ញុំចង់>ឲ្យគាត់ពន្យល់ឃ្លាដែលគាត់បានឆ្លើយនេះ។ <ដូច្នេះ ខ្ញុំ

01354924



មិនអាចស្មានទៅលើ>អ្វីដែលគាត់បានឆ្លើយនេះ <ថាតើ>វាពាក់ព័ន្ធទៅនឹងយុត្តាធិការពេលវេលាដែរ ឬក៏អត់ទេ?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ៊ីចឹងសំណួរជាក់ស្តែង គឺលោកកំពុងតែនិយាយយោងទៅឆ្នាំ១៩៧៥ ឬក៏៧៩ ឬក៏<ពេលណាផ្សេងទៀត>? <អ៊ីចឹងយើងដឹងថា វាអាចមានភាពពាក់ព័ន្ធ។>

[១០:៥៤:៥៧]

**សួរដោយលោក វិុចទ័រ កូប៉េ៖**

**ស៖** ខ្ញុំបានសួរគាត់សំណួរបើកទេ សួរថា “លោកនិយាយហ្នឹងចង់មានន័យថាដូចម្តេច?” ឥឡូវខ្ញុំសួរម្តងទៀត។ លោកសាក្សីនៅពេលដែលលោកនិយាយថា មានតែបក្ខពួក ហ៊ុន សែន ទេដែលទទួលបានផលប្រយោជន៍ពីទ្រព្យសម្បត្តិដែលបាត់បង់ទាំងអស់នៅក្នុងរបប ប៉ុល ពត។ តើលោកចង់និយាយថា ម៉េចហ្នឹង? លោកចង់និយាយចន្លោះពី៧៥-៧៩ ឬយ៉ាងណា?

**ប្រធានអង្គជំនុំ៖**

លោកមេធាវីដើមបណ្តឹងរដ្ឋប្បវេណី!

**<លោក វិុចទ័រ កូប៉េ៖>**

ខ្ញុំទោសលោកប្រធាន សូមមេត្តាកុំកាត់រំខានខ្ញុំ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអភ័យទោសដែលខ្ញុំរំខានលោក។ ក៏ប៉ុន្តែក្នុងឯកសារជាភាសាបារាំង របស់មជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹង ខ្ញុំអត់មានឃើញឃ្លាហ្នឹងទេ។ ជាភាសាបារាំងអត់មានឃ្លាដែលលោកលើកឡើងហ្នឹងទេ ប្រហែលជាពិនិត្យផ្ទៀងផ្ទាត់មើលឯកសារបកប្រែហ្នឹងឡើងវិញ។

**លោក វិុចទ័រ កូប៉េ៖**

អ៊ីចឹង<វាគួរតែជា>ការ<>ឃុបឃិតដោយប្រការណាមួយជាភាសាបារាំងហើយ។ <ខ្ញុំអាចនិយាយបានតែអ្វីដែលខ្ញុំមាននៅក្នុងភាសាអង់គ្លេសតែប៉ុណ្ណោះ។>

[១០:៥៦:០៥]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<សូមឱ្យនរណាមួយមើលជាភាសាខ្មែរមើល!>

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំគិតថា ពាក្យ "បក្ខពួក"ហ្នឹងដែលអត់មានជាភាសាបារាំង ក៏ប៉ុន្តែជាភាសាបារាំង គឺទំព័រ៤៣, <ERN> <00324233> គឺមានសរសេរថា ផលប្រយោជន៍មិនមែនបានទៅខាង ប៉ុល ពត ទេគឺនៅខាងសម្តេច ហ៊ុន សែន។ អ៊ីចឹង <>ពាក្យថា "បក្ខពួក" <អត់មាននៅក្នុងឃ្លានោះទេ>។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

បាទ គឺខ្ញុំនិយាយហ្នឹងគឺ និយាយពាក់ព័ន្ធទៅនឹងទ្រព្យសម្បត្តិដែលត្រូវបានរឹបអូសយកនោះ ផ្នែកហ្នឹងគឺអត់មានទេ<ជាភាសា>បារាំង <ហើយមាននៅក្នុងភាសា>អង់គ្លេស<>។ <ដូច្នេះ នេះជា>ឃ្លាជាក់លាក់<ដែល>មេធាវី កូប៉េ ហ្នឹង <ចង់ឲ្យសាក្សីមានប្រតិកម្ម>កន្លែងត្រង់ហ្នឹង គឺអត់មានទេជាភាសាបារាំង ក្នុងជាភាសាខ្មែរប្រហែលជាមាន ប៉ុន្តែបារាំងខ្ញុំរកអត់ឃើញទេ។

[១០:៥៧:០២]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ជាដំណោះស្រាយខ្ញុំសូមស្នើឲ្យសហការីជាតិរបស់ខ្ញុំ គាត់មើលភាសាដើមជាភាសាខ្មែរតែម្តងដើម្បីរកឃ្លានេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ ខ្ញុំសូមអានតែម្តងទៅជាភាសាខ្មែរ ចំពោះចម្លើយរបស់គាត់ដែលខ្ញុំសូមដកស្រង់ដូចតទៅ៖ "ផលប្រយោជន៍យ៉ាងម៉េច បើវាបាត់សម្បត្តិ ប៉ុល ពត។ អ៊ីចឹងវានៅតែខាងសម្តេច ហ៊ុន សែន ហ្នឹងទៅ។" បាទ ខ្ញុំសូមបញ្ជាក់ត្រង់កន្លែងនេះបន្តិច ពាក្យប្រយោជន៍នេះមិនមានមានសំដៅទៅលើទ្រព្យសម្បត្តិទេ វាសំដៅទៅលើប្រយោជន៍នៃការកាត់ក្តីនេះតែប៉ុណ្ណោះ។ បើយើងពិនិត្យមើលខ្លឹមសារពីខាងលើរបស់គាត់។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី នួន ជា បន្តសំណួរ។

[១០:៥៨:១៩]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំមិនច្បាស់ទេ ថាតើអន្តរាគមន៍ពីខាងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ឥឡូវហ្នឹងច្បាស់លាស់ហើយឬនៅ? -- បាទ អន្តរាគមន៍ពីខាង -- លោកសាក្សី តើលោកសាក្សីកំពុងតែនិយាយថាហ៊ុនសែន នេះគាត់ជាអ្នកប្រមូលយកទ្រព្យសម្បត្តិដែលបានបាត់បង់នៅក្នុងរបប ប៉ុល ពត ហ្នឹងទាំងអស់ឬ?

**លោក ស៊្វយ សៅ៖**

**ឆ៖** ខ្ញុំមិនដឹងដែរនោះឯង។

**ស៖** បាទ សូមអរគុណច្រើនណាស់ ចំណុចនេះចំណុចរសើបបន្តិច ប៉ុន្តែខ្ញុំសូមបញ្ចប់ត្រឹមនេះចុះ។

**ប្រធានអង្គជំនុំ៖**

ជាបន្តសូមអញ្ជើញលោកព្រះរាជអាជ្ញាមាន -- សូមអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណី។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ ដោយសារមានភាពមិនច្បាស់លាស់ដូចសហការីរបស់ខ្ញុំ លោកស្រី ម៉ារី ហ្គីរ៉ូដ៍ បានជម្រាប។ នៅក្នុងនេះវាមានពាក្យថា "បើវាបាត់សម្បត្តិ ប៉ុល ពត" ក៏ប៉ុន្តែន័យជាភាសាខ្មែរអាច វាមិនមានលក្ខណៈច្បាស់លាស់ថាតើសម្បត្តិ ប៉ុល ពត ហ្នឹងមានន័យថាយ៉ាងដូចម្ដេច ជាភាសាបារាំង លោកស្រី ម៉ារី ហ្គីរ៉ូដ៍ យល់ថា បាត់ទ្រព្យសម្បត្តិរបស់ ប៉ុល ពត ហើយដែលត្រូវរឹបអូសដោយអ្នកផ្សេង។ អ៊ីចឹងកន្លែងនេះ ខ្ញុំខ្លាចមានការព្រួយបារម្ភថា មានការបកស្រាយខុសអំពីបញ្ហានេះ។ អ៊ីចឹងពាក្យ "សម្បត្តិ" ដែលជាភាសាខ្មែរលើកឡើងនេះ គឺជាពាក្យមួយដែលមិនមានភាពច្បាស់លាស់ទេ។ បាទ សូមអរគុណលោកប្រធាន។

[១១:០០:២២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី នួន ជា។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ខ្ញុំសូមដកសំណួរនេះចេញទៅវិញ។ ហើយយល់ឃើញថាសម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន គាត់ក៏សប្បាយពាក់ព័ន្ធទៅនឹងចំណុចនេះ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកប្រធាន ខ្ញុំសូមធ្វើការកត់សម្គាល់មួយ។ អ្វីដែលគាត់លើកឡើងហ្នឹង គឺមិនអាចទទួលយកបានទេ។ <ដើម្បីជឿ និងដើម្បីបញ្ចុះបញ្ចូលនរណាម្នាក់ឲ្យជឿតាមចម្លើយនេះ ដែលវាជាបញ្ហា> បច្ចេកទេស<សុទ្ធសាធ គឺពាក់ព័ន្ធ>នឹងបញ្ហានៃការបកប្រែ<នោះ គឺជាការប៉ុនប៉ងធ្វើវិទ្ធង្សនា និងវាយប្រហារទៅលើអ្នកដទៃ។> អ៊ីចឹង អ្វីដែលគាត់ធ្វើហ្នឹង គឺមិនសមស្របទេ។ នេះជាបញ្ហាបច្ចេកទេសបញ្ហាបកប្រែ។ យើងគ្រាន់តែចង់ដឹងថា តើការបកប្រែចេញមកជាភាសាខ្មែរហ្នឹងត្រឹមត្រូវ ឬក៏អត់? ហើយគាត់លើកឡើងអម្បាញ់មិញហ្នឹង គឺជាទង្វើមិនសមរម្យទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញាបន្តសំណួរ -- ចាប់ផ្ដើមសំណួរលើសាក្សីរូបនេះ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

[១១:០១:៥១]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ខ្ញុំនឹងសួរសំណួរលោកតាងនាមឲ្យការិយាល័យសហព្រះរាជអាជ្ញា។ ជាដំបូងខ្ញុំសូមចាប់ផ្ដើមដោយបង្ហាញឯកសារមួយជូនលោក ដែលជាផ្នែកមួយនៃកិច្ចសម្ភាសន៍របស់លោក <ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា>គឺឯកសារ E3/7535 <ឯកសារនេះមានតែ>ជាភាសាខ្មែរគឺ 00087683 រហូតទៅដល់ 690 <វាជាប្រវត្តិរូប>។ ដូច្នេះ លោកប្រធាន ខ្ញុំសូមអនុញ្ញាតប្រគល់ឯកសារនេះជូនទៅសាក្សី។

**ប្រធានអង្គជំនុំ៖**

រដ្ឋបាលតុលាការយកឯកសារហ្នឹងជូនសាក្សី។

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១១:០២:៤៣]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី សូមលោកពិនិត្យមើលឯកសារនេះ ហើយលោកស្គាល់ថាប្រវត្តិរូបហ្នឹងជា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

របស់អ្នកណាទេ? នៅទំព័រទី២ហ្នឹង លោកឃើញមានព័ត៌មានលម្អិត ឧទាហរណ៍ដូចជានៅផ្នែកទី២ <នៃទំព័រទី៥>នុ៎ងគឺមានដាក់ឪពុកម្ដាយ ដាក់អីផងដែរ។ អ៊ីចឹងលោកពិនិត្យមើលៗថា តើប្រវត្តិរូបហ្នឹងជាប្រវត្តិរូបដែលលោកបានបំពេញដោយខ្លួនឯងនៅក្នុងសម័យរបបកម្ពុជាប្រជាធិបតេយ្យមែនទេ?

**ប្រធានអង្គជំនុំ៖**

លោកសាក្សី លោកអាចមើលឃើញអក្សរនៅក្នុងឯកសារនេះទេ?

**លោក ស៊ួយ សៅ៖**

**ឆ៖** មើលៗមិនច្បាស់ទេ ខ្ញុំ។ ភ្នែកអន់ហើយ ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

សុំមន្ត្រីរដ្ឋបាលតុលាការជួយអានឲ្យគាត់ស្ដាប់។

[១១:០៥:០៦]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សម្រាប់ជាកំណត់ត្រាប្រតិចារឹក <ព័ត៌មានពីជីវប្រវត្តិផ្ទាល់ខ្លួនរបស់បុគ្គលដែលធ្វើ> ប្រវត្តិរូបនេះមាននៅលេខជាភាសាខ្មែរ <0087684>*(ស៊ីក)* នៅផ្នែកទី១ <នៃប្រវត្តិរូប ហើយអ្វីដែលអាចជួយដល់សាក្សីផងដែរនោះ គឺ>នៅទំព័រ 00087687 <>នៅផ្នែកទី២ <ដែល>និយាយអំពីឪពុកម្ដាយ ហើយឈ្មោះឪពុកម្ដាយហ្នឹងដូចជាឈ្មោះឪពុកម្ដាយដែលសាក្សីបានផ្ដល់បទសម្ភាសន៍ជូនមជ្ឈ-មណ្ឌលឯកសារកម្ពុជាដែរ។ អ៊ីចឹងខ្ញុំគិតថា<ទាំងពីរ>ហ្នឹងអាចជួយឲ្យសាក្សីដឹងថា តើប្រវត្តិរូបហ្នឹងជារបស់គាត់ ឬក៏មិនមែន?

**ឆ៖** បាទ ត្រឹមត្រូវហើយប្រវត្តិរូបនេះ។

**ស៖** លោកចង់មានន័យថាយ៉ាងម៉េច ត្រឹមត្រូវហ្នឹងបានន័យថា ប្រវត្តិរូបហ្នឹងជាប្រវត្តិរូបរបស់លោកមែនទេ?

**ឆ៖** បាទ ប្រវត្តិរូបនេះជារបស់ខ្ញុំហើយបាទ។

**ស៖** លោកចាំទេ ក្នុងអំឡុងរបបខ្មែរក្រហម ពេលណាដែលលោកបំពេញប្រវត្តិរូបហ្នឹង? លោកចាំឆ្នាំណាទេ? លោកចាំថា លោកបានបំពេញនៅ<ដើមដំបូងនៃរបបនោះ គឺ>ឆ្នាំ៧៥, ឆ្នាំ៧៦ ឬនៅ<ដំណាក់កាលចុងក្រោយនៃរបបនោះ គឺ>នៅ<ឆ្នាំ៧៧ ឬ>ឆ្នាំ៧៨?

[១១:០៦:២៧]

**ឆ៖** បាទ ខ្ញុំអត់ចាំទេ។

**ស៖** សូមឲ្យលោកមើលទំព័រទី៣នៃឯកសារហ្នឹងគឺ <87685>*(ស៊ីក)* <វាគឺជាចម្លើយទៅនឹងសំណួរ>គឺនៅផ្នែកទី១ សំណួរទី១២ នោះ សួរថា<តើលោក>ចូលបដិវត្តន៍ពេលណា<>? បើលោកពិនិត្យមើលឯកសារហ្នឹងទៅក្នុងឯកសារនេះដាក់ថា ចូលបដិវត្តន៍ថ្ងៃទី០១ ខែ០១ ឆ្នាំ១៩៧៥។ ហើយមុននេះលោកថា លោកចូលបដិវត្តន៍នៅឆ្នាំ១៩៧៣ ហើយនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោកជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជាលោកដាក់ថា ៧៤។ អ៊ីចឹងខ្ញុំចង់សួរលោកឲ្យច្បាស់ថា លោកចូលបដិវត្តន៍ហ្នឹងនៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៧៥ ហើយលោកក្រោយមក ក៏ក្លាយទៅជាកងទ័ពខ្មែរក្រហម។ តើអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំដាក់ ៧២តើ តាំងពីឆ្លើយមក -- ប្រាប់មក។

**ស៖** បាទ ប៉ុន្តែអ្វីដែលខ្ញុំសួរលោកនេះ ពេលដែលលោកៗផ្ដល់បទសម្ភាសន៍ជូនមជ្ឈមណ្ឌលឯកសារកម្ពុជានៅឆ្នាំ២០០៥ហ្នឹង គឺ<អត់មានបញ្ជាក់ថា គេបានបង្ហាញប្រវត្តិរូប>ដែលលោកបានសរសេរនៅក្នុង<>សម័យនោះទេ។ នៅក្នុងប្រវត្តិរូបនេះ ក្នុងឯកសារដែលលោកមាននៅនឹងដៃហ្នឹង លោកដាក់ថា ចូលបដិវត្តន៍ថ្ងៃទី០១ ខែ០១ ឆ្នាំ៧៥។ អ៊ីចឹងខ្ញុំសួរថា <តើ>ថ្ងៃ<>ដែលលោកចូលបដិវត្តន៍ហ្នឹងហើយលោកក្លាយទៅជាកងទ័ពហ្នឹង។ ថ្ងៃ០១ ខែ០១ ឆ្នាំ៧៥ ហ្នឹងត្រឹមត្រូវទេ?

[១១:១០:១៥]

**ឆ៖** ដូចវាមិនត្រូវ -- អ៊ូ! ត្រឹមត្រូវហើយបាទ។

**ស៖** ក្រោយចូលធ្វើជាកងទ័ពខ្មែរក្រហម នៅថ្ងៃ០១ ខែ០១ ឆ្នាំ៧៥មកហ្នឹង ពេលណាដែលគេបញ្ជូនលោកទៅវាយប្រយុទ្ធជាមួយនឹងកម្លាំងកងទ័ពរបស់ លន់ នល់ នោះ?

**ឆ៖** បញ្ជូនមកតាំងពី៧២។ ពីឆ្នាំមួយពាន់ប្រាំបួនរយ -- អ៊ំ ពីឆ្នាំ -- ពីឆ្នាំ៧២អ៊ីចេះឯង ដែលគេបញ្ជូនខ្ញុំតាំងពីឆ្នាំ៧២។

**ស៖** បាទ ខ្ញុំចង់ឲ្យប្រាកដនូវចម្លើយរបស់លោក។ លោកចង់ឆ្លើយថា លោកចូលកងទ័ពប្រយុទ្ធជាមួយនឹងកងទ័ព លន់ នល់ ហ្នឹង នៅឆ្នាំ៧២ហ្នឹង មែនទេ <គឺបីឆ្នាំមុនពេលលោកចូលកងទ័ពបដិវត្តន៍>?

**ឆ៖** គេបញ្ជូនមក៧២ ហើយ។

**ស៖** បញ្ជូនលោកនៅឆ្នាំ៧២ហ្នឹង បញ្ជូនទៅណា?

**ឆ៖** បញ្ជូនឡើងមកវ៉ៃភ្នំពេញ។

**ស៖** គេបញ្ជូនលោកមកវាយនៅភ្នំពេញហ្នឹង ឆ្នាំ៧២ ឬឆ្នាំ៧៥?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

សាក្សី! ចាំមីក្រូហ្វូនប្រតិបត្តិការចេញភ្លើងក្រហម ចាំឆ្លើយ។

**លោក ស៊្វយ សៅ៖**

**ឆ៖** បញ្ជូន៧២ មកវ៉ៃភ្នំពេញតែម្តង វាយប្រហារភ្នំពេញនេះឯង ជំនាន់លន់ នល់។

[១១:១២:០០]

**ស៖** ឥឡូវ ខ្ញុំសួរសំណួរផ្សេងវិញ។ មុនពេលគេបញ្ជូនលោកទៅវាយជាមួយនឹងកងទ័ព លន់ នល់ហ្នឹង លោកមានបានហ្វឹកហ្វឺនធ្វើជាយុទ្ធជនទេ?

**ឆ៖** អត់បានហ្វឹកហ្វឺនផង។ ដល់ គេបញ្ជូនបំពាក់កាំភ្លើងវ៉ៃបណ្តោយ។

**ស៖** លោកចូលកងទ័ពខ្មែរក្រហមហ្នឹង ចូលដោយស្ម័គ្រចិត្ត ឬក៏គេបង្ខំឲ្យលោកចូលធ្វើជាកងទ័ព?

**ឆ៖** បាទ គេបង្ខំខ្ញុំឲ្យ កុំអីមកធ្វើអី។

**ស៖** អ្នកណាជាអ្នកបង្ខំលោកឲ្យចូលធ្វើជាកងទ័ពខ្មែរក្រហម?

**ឆ៖** អាគេខាង នៅខាងឃុំនោះឯង។ មន្ទីរឃុំគេនោះឯង។

**ស៖** សំណួរចុងក្រោយពាក់ព័ន្ធនឹងប្រវត្តិរូបនេះ សូមលោកពិនិត្យមើលទំព័រមុខ គឺក្របមុខប្រវត្តិរូប<របស់លោក>នៅសម័យកម្ពុជាប្រជាធិបតេយ្យ។ នៅក្របមុខនេះ មានបញ្ជាក់អំពីកងរបស់លោក គឺនៅក្នុងនេះ ដាក់ថាលោកជាយុទ្ធជនកងពល៣១០ វរសេនាធំ១១ វរសេនាធំតូច១១២ អនុសេនាធំទី១។ តើចំណុចនេះ ធ្វើឲ្យលោកនឹកឃើញឡើងវិញទេថា លោកធ្វើជាយុទ្ធជននៅកងអនុសេនាធំទី១ វរសេនាតូច១១២ វរសេនាធំ១១ និងកងពល៣១០?

[១១:១៥:១២]

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** តើនៅក្នុងកងអនុសេនាធំទី១ នៃវរសេនាតូច១១២ លោកមានគ្នាប៉ុន្មាននាក់ដែរ យុទ្ធជនសរុបហ្នឹងប៉ុន្មាននាក់នៅក្នុងកងអនុសេនាធំទី១ហ្នឹង?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឆ៖ មាន១០០នាក់។

ស៖ អ្នកណាជាមេបញ្ជាការកងអនុសេនាធំទី១របស់លោកនេះ?

ឆ៖ ភ្លេចឈ្មោះបាត់ហើយ។ គេចាប់យកទៅអស់ទៅហើយនោះ។

ស៖ ពេលណាដែលមេកងអនុសេនាធំទី១ត្រូវចាប់ខ្លួន បើធៀបពេលដែល តាអឿន ចាប់ខ្លួននោះ តើមេកងអនុសេនាធំរបស់លោកហ្នឹង ចាប់ខ្លួននៅពេលណាដែរ?

ឆ៖ មួយសារដេញដោលគ្នាហ្នឹងឯង។

ស៖ លោកអាចជម្រាបឲ្យបានច្បាស់បន្តិចបានទេ ថាតើប្រធានកងអនុសេនាធំរបស់លោកហ្នឹង ត្រូវបានចាប់ខ្លួនមុន ឬក៏ក្រោយពេលគេចាប់ខ្លួនតាអឿន លេខាកងពល៣១០ ពេលណាដែលគេចាប់មេបញ្ជាការកងពលអនុសេនាធំរបស់លោកនេះ?

[១១:១៧:១៩]

ឆ៖ មួយសាគ្នាហ្នឹងឯង សាកងពលហ្នឹងហើយ។

ស៖ ចុះមេបញ្ជាការវរសេនាតូច១១២ លោកចាំឈ្មោះគាត់ទេ មេបញ្ជាការវរសេនាតូចហ្នឹងឈ្មោះអីដែរ?

ឆ៖ ខ្ញុំភ្លេចឈ្មោះបាត់ហើយ។

ស៖ ចុះមេបញ្ជាការវរសេនាធំលេខ១១ លោកចាំឈ្មោះគាត់ទេ?

ឆ៖ ភ្លេចបាត់ហើយ។ មិនចំណាំទេ ខ្ញុំភ្លេចអស់បាត់ហើយ។

ស៖ ចុះយុទ្ធជនដែលធ្វើការក្នុងកងអនុសេនាធំទី១របស់លោកនោះ លោកមានចាំឈ្មោះយុទ្ធជនណាខ្លះដែលធ្វើការនៅក្នុងកងអនុសេនាធំទី១ ជាមួយលោកនោះ?

ឆ៖ បែកបាក់គ្នាស្លាប់អស់ខ្លះហើយ។

ស៖ ខ្ញុំគ្រាន់តែចង់សួរឈ្មោះទេ លោកចាំឈ្មោះអ្នកណាម្នាក់ទេ អ្នកដែលធ្វើការជាមួយលោកក្នុងកងអនុសេនាធំទី១ហ្នឹង?

[១១:១៩:១១]

ឆ៖ វាភ្លេចអស់ទៅហើយណ៎ា ឈ្មោះគេនោះ វាយូរណាស់ហើយ ចាស់ស្លាប់ទៅខ្លះទៅអីទៅក៏វាភ្លេចបាត់អស់ហើយ។

ស៖ លោកចាំទេថា មានអ្នកណាខ្លះនៅក្នុងកងអនុសេនាធំទី១ហ្នឹង ដែលត្រូវបានចាប់ខ្លួន ឬ

បាត់ខ្លួននៅក្នុងរបបខ្មែរក្រហមនោះ?

**ឆ៖** ខ្ញុំវាចាំមិនបានទេ។

**ស៖** ខ្ញុំសួរលោកបែបនេះ ដោយសារថា នៅក្នុងសំណុំរឿងយើងនេះ សហចៅក្រមស៊ើបអង្កេតបានធ្វើបញ្ជីអ្នកទោសដែលត្រូវបានបញ្ជូនទៅមន្ទីរស-២១ ហើយកងពល៣១០របស់លោកហ្នឹង គឺត្រូវបានធ្វើការបោសសម្អាត ហើយនៅក្នុងបញ្ជីរបស់ អូ.ស៊ី.អាយ.ជេ ហ្នឹងសរុបទៅគឺ ១.១៣៥នាក់ មកពីកងពល៣១០ ដែលត្រូវបានចាប់ខ្លួន និងបញ្ជូនទៅស-២១ ហើយអ្នកភាគច្រើនហ្នឹង គឺជាយុទ្ធជនសាមញ្ញធម្មតា។ អ៊ីចឹង ខ្ញុំចង់សួរលោកថា យុទ្ធជន១០០នាក់ ដែលនៅក្នុងកងអនុសេនាធំរបស់លោកហ្នឹង លោកដឹងថាមានអ្នកណាបាត់ខ្លួន ឬក៏ត្រូវបានគេចាប់ខ្លួនទេ<នៅក្នុងអំឡុងពេលរបបនោះ>?

**ឆ៖** អានោះ ខ្ញុំមិនសូវដឹងដែរ អារឿងបាត់ខ្លួននោះ។

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយអំពីបញ្ជីស-២១ ពាក់ព័ន្ធនឹងការចាប់ខ្លួនមនុស្សមកពីកងពលរបស់លោកនេះនៅពេលក្រោយទៀត។ ឥឡូវនេះ ខ្ញុំចង់ពិភាក្សាលោក -- ជាមួយលោកអំពីពេលដែលលោកប្រចាំការនៅភ្នំពេញក្នុងកងពល៣១០។ ពេលលោកឈរជើងនៅទួលគោក តើគេអនុញ្ញាតឲ្យលោកដើរហើរដោយសេរីនៅក្នុងទីក្រុងទេ ឬក៏លោកត្រូវមានលិខិតបើកផ្លូវដើម្បីលោកធ្វើដំណើរទៅណាមកណានៅក្នុងទីក្រុងនោះ?

[១១:២២:០៦]

**ឆ៖** មិនដែលដើរទៅណាផង នៅចាំតែកន្លែងនុំងឯង។

**ស៖** ហើយនៅទួលគោកហ្នឹង តើមានកម្មាភិបាលកងពល៣១០ហ្នឹងប៉ុន្មាននាក់ដែរ?

**ឆ៖** អារឿងនោះ ខ្ញុំក៏វាចាំមិនបានដែរ អារឿងនោះៗ។

**ស៖** លោកអាចផ្ដល់តួលេខប្រហាក់ប្រហែលបានទេ តិចជាង១០០ ឬក៏ច្រើនជាង១០០?

**ឆ៖** នៅភ្នំពេញនោះ វាខ្លាំងណាស់មិនដល់ ១០០នាក់ផង ទ័ពដែលនេះនោះ។

**ស៖** ក្នុងពេលលោកធ្វើការឲ្យកងពល៣១០នៅភ្នំពេញ តើលោកធ្លាប់ចូលរួមកិច្ចប្រជុំ ថ្នាក់កងពល វរសេនាធំ វរសេនាតូច ឬក៏កងអនុសេនាធំអីទេ មានការប្រជុំអីជាទៀងទាត់ទេ?

**ឆ៖** ខ្ញុំយុទ្ធជនហ្នឹង គេដែលហៅប្រជុំអីប៉ុន្មាន។

**ស៖** លោកបាននិយាយជាច្រើន<ដង>ថាលោកនៅក្មេង លោកគ្រាន់តែជាយុទ្ធជន លោកមិនដែលបានចូលរួមប្រជុំអីទេ។ អ៊ីចឹងត្រឹមត្រូវទេ បើខ្ញុំនិយាយថា លោកមិនមានព័ត៌មានអីច្រើនទេ អំពី

សកម្មភាព ឬក៏ផែនការរបស់ថ្នាក់ដឹកនាំកងពលរបស់លោកនោះ ព្រោះថាលោកជាយុទ្ធជនសាមញ្ញតែប៉ុណ្ណោះ។ លោកសាក្សី ខ្ញុំសួរអម្បាញ់មិញនេះ សួរលោកថាក្នុងឋានៈលោកជាយុទ្ធជនសាមញ្ញនោះ លោកដឹងថាតើមេដឹកនាំកងពលហ្នឹងធ្វើអ្វីខ្លះទេ? លោកដឹងថាពួកគាត់មានផែនការ ឬក៏មានសកម្មភាពអ្វីខ្លះទេ?

[១១:២៥:២៧]

**ឆ៖** ខ្ញុំក៏មិនសូវដឹងដែរអារឿងនោះ បញ្ហានោះ។

**ស៖** តើលោកឃើញលេខាកងពល អឿន ហ្នឹងញឹកញាប់ប៉ុនណាដែរ ហើយនៅភ្នំពេញហ្នឹងគាត់ស្នាក់នៅកន្លែងណា?

**ឆ៖** មិនសូវជួបគាត់ញឹកញយប៉ុន្មានទេខ្ញុំនោះ។

**ស៖** <ពេលលោកនិយាយថា> "មិនសូវញឹកញយហ្នឹង" <តើជួបគាត់>ប៉ុន្មានដង<នៅក្នុងរបបនោះ គឺ>តាំងពីឆ្នាំ៧៥ រហូតទៅដល់ពេលដែលគេចាប់គាត់នៅខែកុម្ភៈ ឆ្នាំ៧៧ហ្នឹង លោកឃើញគាត់ប៉ុន្មានដងដែរ?

**ឆ៖** មិនសូវដែរឃើញគាត់ផងណា ព្រោះខ្ញុំមកនៅឯទួលគោកនេះ គាត់នៅភ្នំពេញឯណេះ ខុសគ្នា។

**ស៖** ព្រោះថាលោកនិយាយថាលោកមិនសូវជួបញឹកញយ អ៊ីចឹងបានខ្ញុំសួរបញ្ជាក់លោកថា មិនសូវញឹកញយហ្នឹងប៉ុន្មានដង តិចជាងប្រាំដង តិចជាង១០ដង ឬក៏តែមួយដង ពីរដង លោកអាចប្រាប់ប្រហាក់ប្រហែលបានទេ ថាលោកជួបលេខាកងពល អឿន ហ្នឹងប៉ុន្មានដង?

[១១:២៧:០០]

**ឆ៖** មិនដែលសូវជួបទេ ខ្ញុំនោះ វាយុទ្ធជននោះមិនដែលសូវជួបមេកងពលឯណា។

**ស៖** លោកអាចរៀបរាប់អំពីភិនភាគ ឬក៏រូបរាងរបស់ អឿន បានទេ?

**ឆ៖** រាប់មិនបានទេ បើខ្ញុំវាមិនសូវនេះដែរ។

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយលម្អិតពីចំណុចនេះនៅក្រោយពេលឈប់សម្រាកអាហារថ្ងៃត្រង់។ ប៉ុន្តែឥឡូវនេះខ្ញុំចង់និយាយអំពីកិច្ចប្រជុំមួយដែលលោកបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយដែលមេធាវីការពារក្តីបានសួរលោកជាច្រើន។ គឺកិច្ចប្រជុំជាមួយលេខាកងពល៣១០ឈ្មោះ អឿន។ ខ្ញុំសូមដកស្រង់ លោកឆ្លើយថា "ខ្ញុំមិនចាំទេ ពីព្រោះថាខ្ញុំនៅខាងក្រោយ"។ លោកចង់មានន័យថាម៉េច

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ពេលដែលលោកនិយាយថាលោកនៅខាងក្រោយនោះ?

**ឆ៖** ព្រោះពេលនោះ ខ្ញុំនៅឆ្ងាយពីគាត់នោះ។

**ស៖** ឆ្ងាយពីគាត់ហ្នឹងប៉ុន្មានម៉ែត្រដែរ ហើយពេលប្រជុំហ្នឹងគេប្រជុំនៅកន្លែងណា?

**ឆ៖** ប្រជុំនៅភ្នំពេញនេះឯងណ៎ា។ ខ្ញុំនៅឯណា នៅជិតនៅទួលគោកចុងឯលិចនោះ។

[១១:២៩:០៩]

**ស៖** អ៊ីចឹងលោកទៅពីមូលដ្ឋានរបស់លោកទៅទួលគោកហ្នឹង ទៅប្រជុំនៅភ្នំពេញហ្នឹង លោកធ្វើដំណើរទៅយ៉ាងម៉េច?

**ឆ៖** អាបើទៅៗដើរ។

**ស៖** មានអ្នកណា មានមនុស្សប៉ុន្មាននាក់ដែលដើរជាមួយលោកពីទួលគោកទៅប្រជុំនៅភ្នំពេញនោះ?

**ឆ៖** មួយសានោះវាភ្លេចអស់បាត់ហើយ ពីរបីនាក់នោះឯងទៅនោះ ភ្លេចអស់បាត់ហើយ។

**ស៖** លោកដើរទៅប្រជុំនៅភ្នំពេញហ្នឹង លោកដើរដោយរបៀបលាក់លៀម លាក់ខ្លួនមិនឲ្យគេដឹង ឬក៏លោកដើរធម្មតានៅលើផ្លូវ អ៊ីចឹងឲ្យគេឃើញជាធម្មតា?

**ឆ៖** ដើរធម្មតាយើងទេ តាមថ្នល់អ៊ីចឹងឯង។

**ស៖** ហើយ<ធ្វើម៉េច>លោក<ដឹងថាត្រូវទៅកន្លែងណា តើកន្លែង>ប្រជុំ<>សម្ងាត់ហ្នឹងនៅ<កន្លែងណា>?

**ឆ៖** ចេញពីទួលគោកមកសំដៅជ្រោយចង្វាកាច់មកត្បូងមក យើងដើរតើ។

**ស៖** បាទ សំណួរចុងក្រោយលោកប្រធាន មុនពេលឈប់សម្រាក។ ខ្ញុំចង់ដឹងថា អ្នកណាជាអ្នកប្រាប់លោកថាត្រូវទៅ<កន្លែង>ណាៗនោះ? គ្នាលោកដែលថាទៅពីរបីនាក់ហ្នឹង មានអ្នកណាគេប្រាប់ទេថាត្រូវដើរតាមផ្លូវណា ដើម្បីទៅដល់កន្លែងប្រជុំហ្នឹង?

**ឆ៖** កន្លែងប្រជុំហ្នឹងខ្ញុំក៏មិនដឹងដែរ មិនដឹងអីដែរ។

**ស៖** បាទ លោកប្រធាន។ ខ្ញុំគិតថាជាពេលសមស្រប ដើម្បីឈប់សម្រាកហើយ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា។

ឥឡូវដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូត

ដល់ម៉ោងមួយកន្លះរសៀល សូមអញ្ជើញចូលវិញបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីអ្នកជំនាញដល់សាក្សីរូបនេះ ឈប់ក្នុងអំឡុងពេលឈប់សម្រាកថ្ងៃត្រង់ និងអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងមួយកន្លះរសៀលនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួន លោក ខៀវ សំផន ទៅកាន់បន្ទប់រងចាំខាងក្រោមសាលសវនាការ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សូមអញ្ជើញសម្រាក!

*(សវនាការសម្រាកពីម៉ោង ១១:៣៣ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣០:២៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តសវនាការ។

សូមអញ្ជើញលោកព្រះរាជអាជ្ញាមានសំណួរបន្ត។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ជម្រាបសួរលោកសាក្សី។ មុនពេលឈប់សម្រាក យើងបាននិយាយគ្នាអំពីកិច្ចប្រជុំមួយដែលលោកបានរៀបរាប់នៅក្នុងចម្លើយឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជាថា អង្គប្រជុំនេះ គឺថាមានការពិភាក្សាគ្នាអំពីផែនការវាយប្រយុទ្ធដណ្តើមយកទីក្រុងភ្នំពេញ។ តើកិច្ចប្រជុំនោះ គេប្រារព្ធធ្វើឡើងនៅទីកន្លែងណាដែរ? <តើលោកអាចរៀបរាប់បានទេថាតើទីតាំងនៅកន្លែងណា?> តើការប្រជុំនេះ គេប្រជុំនៅក្នុងអគារណាមួយ ឬក៏គេប្រជុំនៅក្រៅអគារ?

**លោក ស៊ួយ សៅ៖**

**ឆ៖** អាហ្នឹងខ្ញុំក៏មិនដឹងដែរ។

**ស៖** តើការប្រជុំនេះ គេប្រជុំនៅក្នុងអគារ ឬក៏គេប្រជុំនៅក្រៅអគារ?

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01354936



**ឆ៖** បាទ ខ្ញុំអត់ដឹងដែរ រឿងហ្នឹង។

**ស៖** លោកបាននិយាយថា នៅក្នុងអង្គប្រជុំនេះគឺមានអ្នកចូលរួមប្រមាណជា១០០នាក់ ត្រឹមត្រូវដែរទេ?

**ឆ៖** បើខ្ញុំមិនដឹង ដឹងស្អី។

[១៣:៣២:៥៧]

**ស៖** លោកបានឆ្លើយថា លោកនឹកមិនឃើញទេពីរឿងអង្គប្រជុំនេះ ដោយសារថាលោកអង្គុយនៅជួរក្រោយនោះ ឆ្ងាយណាស់។ តើលោកអង្គុយ បើគិតពីចម្ងាយពីលោកអង្គុយទៅកន្លែងអ្នកដែលគេបើកអង្គប្រជុំហ្នឹងចម្ងាយប៉ុន្មាន? តើលោកអង្គុយហ្នឹងវាឆ្ងាយមែនទែនស្តាប់មិនបាន ឬក៏យ៉ាងណា?

**ឆ៖** អត់ដឹងតែម្តង ខ្ញុំមិនបាននេះផង។

**ស៖** លោកសាក្សី គេសួរលោកថា តើពីកន្លែងអង្គុយហ្នឹង តើពីកន្លែងដែលលោកអង្គុយនៅក្នុងអង្គប្រជុំហ្នឹង ទៅកន្លែងអ្នកដែលបើកអង្គប្រជុំហ្នឹងវាឆ្ងាយពេកស្តាប់មិនឮ ឬក៏យ៉ាងម៉េចដែរ លោកយល់ទេ?

**ឆ៖** ថាខ្ញុំមិនបានចូលរួមប្រជុំនឹងគេនោះទេ។

**ចៅក្រម ក្លូឌា ហ្វេនស៖**

ប្រហែលជាដោយសារតែការបកប្រែទេដឹង ដោយសារថាមានពាក្យថា នៅខាងក្រោយនោះ។ ប្រហែលជា<ចង់និយាយថា មិនមែន>អង្គុយ<នៅខាងមុខទេ ប៉ុន្តែគឺអង្គុយនៅកន្លែងណាមួយ -- ដូច្នេះការបកប្រែអាចបញ្ជាក់រឿងនេះបាន។>

**សួរដោយលោក ខេល លីសាក់៖**

**ស៖** ព្រឹកមិញនេះ លោកនិយាយថា លោកអង្គុយនៅខាងក្រោយ តើលោកអង្គុយនៅខាងក្រោយខ្នង ឬក៏ខាងក្រោយជួរហ្នឹង ឬក៏ថាលោកមិនបានចូលរួមប្រជុំទេ?

**លោក ស៊្វយ សៅ៖**

**ឆ៖** បាទ បើខ្ញុំមិនបានចូលរួមប្រជុំមែន ថ្ងៃនោះ។

[១៣:៣៥:១៤]

**ស៖** ខ្ញុំនឹងត្រឡប់មកសួរលោកចំណុចនេះវិញនៅពេលក្រោយ។ ឥឡូវនេះ ខ្ញុំចូលទៅសួរចំណុចមួយទៀត ដែលលោកឆ្លើយជូនជម្លូមណ្ឌលឯកសារកម្ពុជាដែរ ហើយដែលមេធាវីការពារក្តីបាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សួរលោករួចហើយ គឺការចូលរួមពាក់ព័ន្ធរបស់លោក នៅក្នុងការដឹកជញ្ជូនអាវុធយុទ្ធភណ្ឌ។ ឲ្យមែនទែនពិតប្រាកដទៅថា តើលោកនេះ បានដឹកជញ្ជូនអាវុធហ្នឹងនៅពេលណាដែរ? តើលោកដឹកជញ្ជូនអាវុធនេះ នៅមុនពេលលោកជួបប្រជុំជាមួយ តាអឿន ឬក៏ក្រោយពេលប្រជុំទេ? បាទ អ៊ីចឹង តើលោកដឹកជញ្ជូនអាវុធ<>នេះ នៅពេលណាដែរ?

**ឆ៖** ខ្ញុំមិនបានដឹកទេ។ ខ្ញុំយុទ្ធជន នៅកន្លែងនោះ មិនបានដឹកឯណា អត់។

**លោក វ៉ិចទ័រ កូប៉េ៖**

មិនមែនជាការជំទាស់ទេលោកប្រធាន។ ក៏ប៉ុន្តែជាសំណើសុំមួយ ដើម្បីសុំឲ្យបិទទ្វារ ដោយសារតែខ្ញុំមានការ<កត់សម្គាល់ថា មានអ្វីចម្លែកនៅក្នុងចម្លើយរបស់សាក្សីរូបនេះ ហើយខ្ញុំ>ចង់<ស្នើសុំអង្គជំនុំជម្រះថាតើ>សាក្សីនេះ<មានទំនាក់ទំនងណាមួយទេ។ ខ្ញុំគិតថា អង្គភាពគាំពារអ្នកជំនាញនិងសាក្សីអាចមានការពាក់ព័ន្ធ។>។ អ៊ីចឹងហើយបានជាស្នើសុំ<ឲ្យបិទទ្វារ។>

[១៣:៣៦:៥៤]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកប្រើពាក្យ "បិទទ្វារ"នេះ លោកកំពុងឲ្យបើកសវនាការអសាធារណៈ ឬក៏យ៉ាងម៉េចនេះពាក្យនេះ?

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ គឺសុំឲ្យមានសវនាការអសាធារណៈ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើហេតុផល មូលហេតុអីដែរ ដែលសុំឲ្យមានសវនាការអសាធារណៈ?

**លោក វ៉ិចទ័រ កូប៉េ៖**

<>ការកែប្រែចម្លើយរបស់គាត់<ភ្លាមៗនេះ ធ្វើឲ្យ>ខ្ញុំក្រោកឈរឡើង ស្នើសុំថា សុំឲ្យបើកសវនាការអសាធារណៈជាមួយសាក្សីរូបនេះ<មួយរយៈពេលខ្លី ដើម្បីចង់ដឹងថាតើមានអ្វីកើតឡើងនៅក្នុងអំឡុងពេលញ៉ាំបាយថ្ងៃត្រង់ជាមួយសាក្សីរូប>នេះ។

[១៣:៣៧:២៦]

**លោក ឌេល លីសាក់៖**

ខ្ញុំមិនយល់ថា ហេតុអីបានយើងត្រូវបើកសវនាការអសាធារណៈ? ខ្ញុំ<មិន>ជំទាស់<ទេ> បើ

សិន<>អង្គជំនុំជម្រះ<សួរគាត់នៅពេលនេះ> ថាតើគាត់មានអ្នកណាទាក់ទងគាត់ពេលបាយថ្ងៃត្រង់នេះ ឬក៏យ៉ាងណានោះ <ប៉ុន្តែខ្ញុំមិនយល់ថាហេតុអ្វីបានជាយើងចាំបាច់ត្រូវធ្វើសវនាការអសាធារណៈនោះ> ទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

មើលទៅហាក់បីដូចជាគាត់បដិសេធមិនឆ្លើយ មើលទៅ។ អ៊ីចឹងយើងសាកបើកសវនាការអសាធារណៈមើល។

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៣៩:៣០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អង្គជំនុំជម្រះបដិសេធសំណើសុំបើកសវនាការអសាធារណៈ ដោយសារថាសាក្សី ដោយមូល-ហេតុថាសាក្សីបានផ្លាស់ប្តូរចម្លើយរបស់ខ្លួន នោះគឺថាមិនមែនជាមូលហេតុមួយសមហេតុសមផលនោះទេ។ <ហើយ>បន្ថែម<ពីលើនោះទៀត ការចោទប្រកាន់ដោយគ្មានភស្តុតាង> ឬការលើកឡើងណាថាមានអ្វីគេនិយាយអ្វីជាមួយគាត់នៅក្នុងពេលពិសាបាយថ្ងៃត្រង់<នោះ ឥឡូវនេះគឺត្រូវបានលើកយកមកនិយាយនៅក្នុងសវនាការសាធារណៈនេះរួចហើយ ដូច្នេះវាឈ្នះលើ>ការស្នើសុំបើកសវនាការអសាធា-រណៈ<>នោះ<ហើយ>។

**ប្រធានអង្គជំនុំ៖**

សូមលោកព្រះរាជអាជ្ញាបន្តសំណួរ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី លោកបានរៀបរាប់នៅក្នុងចម្លើយឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា និយាយអំពីការដឹកអាវុធតាមឡានកាំមីញ៉ុង ឯលោកឆ្លើយថាលោកអត់បានដឹកអាវុធនោះទៅវិញ។ អ៊ីចឹងតើអ្នកណាជាអ្នកដឹកអាវុធនោះ ហើយលោកដឹងថាគេដឹកអាវុធចូលមកភ្នំពេញហ្នឹងដឹងដោយរបៀបណា?

**លោក ស៊្វីយ សៅ៖**

**ឆ៖** ដឹងតាមទ័ពនិយាយដែរហ្នឹងណ៎ាបាទ។

[១៣:៤១:១១]

**ស៖** តើលោកដឹងថា គេដឹកយកអាវុធហ្នឹងមកពីទីកន្លែងណា? ហើយដឹកឆ្ពោះទៅកន្លែងណាដែរ? លោកដឹងព័ត៌មានលម្អិតទេ?

**ឆ៖** បាទ ខ្ញុំមិនដឹងហើយ បានខ្ញុំឆ្លើយទៅមិនរួចហ្នឹង។

**ស៖** ហើយអង្គប្រជុំដែលលោកបានរៀបរាប់នៅក្នុងចម្លើយឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុ-ជាដែលថា លេខាកងពលឈ្មោះ អឿន នេះគឺបាននិយាយអំពីផែនការវាយប្រហារមួយ ឬក៏ផែនការធ្វើរដ្ឋប្រហារនៅក្នុងទីក្រុងភ្នំពេញ។ បើសិនបើលោកមិនមានវត្តមាននៅក្នុងអង្គប្រជុំនេះទេ តើលោកឮព័ត៌មាននេះមកពីអ្នកណា? ឈ្មោះអ្វីដែរ?

**ឆ៖** ដឹងតែគេរ៉ៃៗ ប៉ុន្តែខ្ញុំមិនដឹងផែនការគេរ៉ៃថ្ងៃណាប៉ុណ្ណោះឯង។

**ស៖** តើលោកនៅចងចាំបានទេថា លោកឮព័ត៌មាននេះមកពីប្រភពណា? មកពីអ្នកណាដែរ?

**ឆ៖** ឮពីអង្គភាពទ័ពជាមួយគ្នានេះឯងបាទ។

**ស៖** នៅក្នុងអង្គភាពរបស់លោកហ្នឹងគឺជាអ្នកណាដែរហ្នឹង?

**ឆ៖** ណាបើវាស្លាប់បាត់អស់ទៅហើយហ្នឹង។

[១៣:៤៣:១៦]

**ស៖** បាទ ខ្ញុំយល់ហើយ ស្តាប់ ក៏ប៉ុន្តែតើលោកនៅចាំឈ្មោះមនុស្សដែលនិយាយប្រាប់លោកអំពីអង្គប្រជុំនេះទេ?

**ឆ៖** ខ្ញុំបាទមិនចាំទេរឿងនោះ។

**ស៖** តើលោកដឹងទេថា អង្គប្រជុំហ្នឹងគេធ្វើឡើងនៅអំឡុងពេល ប្រហែលជាអំឡុងពេលណាដែរ? ខ្ញុំមិនសួរឲ្យលោកឆ្លើយឲ្យចំថា ប្រជុំខែណាឆ្នាំណាទេ គ្រាន់តែសួរថា បើនិយាយប្រហែលៗហ្នឹងគឺពេលវេលា<នៃការប្រជុំហ្នឹង>នៅក្នុងអំឡុងពេលណាដែរ បើលោកធៀបទៅនឹងពេលវេលាចាប់ខ្លួនតាអឿន នោះណ៎ា? តើ<តាអឿន ត្រូវបានគេចាប់ខ្លួនពីរបីថ្ងៃក្រោយ>ការប្រជុំនេះ<ឬ? តើមួយអាទិត្យឬក៏មួយខែក្រោយការប្រជុំ ទើបគេចាប់ខ្លួន> តាអឿន <>?

**ឆ៖** ខ្ញុំបាទក៏មិនដឹងដែររឿងនោះហ្នឹងបាទ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** មេធាវីការពារក្តីបានសួរលោកកាលពីព្រឹកមិញនេះ ថាតើលោក<ចាំពីកិច្ច>ប្រជុំ<មួយ><>ដែលគេចាក់សំឡេង<ឆ្លើយសារភាពរបស់>លេខាកងពលឈ្មោះ តាអឿន នោះដែរឬក៏អត់។ ហើយខ្ញុំសូមជួយរំឭកដល់ការចងចាំរបស់លោក ដោយអានសម្រង់នៃចម្លើយរបស់លោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា។

[១៣:៤៥:០២]

លោកប្រធាន នេះគឺឯកសារ E3/7535, ERN ជាភាសាខ្មែរ 00087827, អង់គ្លេស 00324176, បារាំង 00324217 ហើយនេះ គឺជាអ្វីដែលលោកបានឆ្លើយនៅក្នុងកិច្ចសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា។ "សួរ៖ តើលោកដឹងថា គេដឹក តាអឿន យកទៅទីណាទេ? ឆ្លើយ៖ ក្រោយមក គេហៅយើងឲ្យប្រជុំ ទើបបានប្រាប់អំពីរឿងចាប់ខ្លួននេះ។ ពួកគេបាននិយាយថា មេរបស់ពួកឯងហ្នឹង ត្រូវបានចោទថាក្បត់ជាតិ ហើយគេចាប់ខ្លួនបាត់ទៅហើយ។ សួរ៖ តើអ្នកណាហៅទៅប្រជុំនោះ? ឆ្លើយ៖ ខ្ញុំនឹកឈ្មោះអ្នកប្រាប់នេះមិនឃើញទេ។ គាត់ម្នាក់នោះ គឺថាមានភ្នែករាងក្រហម។ សួរ៖ ចុះគាត់និយាយថាម៉េចដែរ? ឆ្លើយ៖ គាត់ឆ្លើយថា អ្នកឯងនេះមានបំណងចង់វាយប្រហារយកទីក្រុងភ្នំពេញ។ ឥឡូវនេះ មេរបស់ឯងគេចាប់ហើយ។ ទើបបានបន្ទាប់មកគេចាក់កាសែតឲ្យស្តាប់។ គេចង់ឲ្យពួកយើងខ្ញុំស្តាប់ឮសូរសំឡេង តាអឿន។ សួរ៖ ចុះតាអឿន និយាយថាម៉េចដែរ? ឆ្លើយ៖ តាអឿន បាននិយាយថា <គាត់>បានក្បត់ ប៉ុល ពត នេះ ច្រើនឆ្នាំមកហើយ ចាប់តាំងពីរដ្ឋប្រហារ១៩៧០ មកម្ល៉េះ។" ខ្ញុំបញ្ចប់ការដកស្រង់។

លោកសាក្សី តើត្រង់ចំណុចនេះ វាជួយរំឭកដល់ការចងចាំរបស់លោកដែរឬទេ? <តើលោកចាំពី>អង្គប្រជុំមួយក្រោយការចាប់ខ្លួន តាអឿន <ដែលដឹកនាំដោយបុរសម្នាក់ ដែលលោករៀបរាប់ថាមាន>ភ្នែករាងក្រហម ហើយនៅពេលប្រជុំហ្នឹង គេចាក់ខ្សែអាត់សំឡេង តាអឿន ហ្នឹងឲ្យស្តាប់ផង? លោកចាំពីចំណុចទាំងអស់នេះ ដែរឬទេ?

[១៣:៤៧:១៩]

**ធ៖** អ៊ូ! ខ្ញុំមិនចាំទេ ភ្លេចបាត់ទៅហើយ បាទ។

**ស៖** លោកសាក្សី តើវាអាចដែរឬទេ ថាព័ត៌មានដែលលោកទទួលបានមកហ្នឹង គឺវាពាក់ព័ន្ធទៅនឹងផែនការរដ្ឋប្រហារទៅនឹង អឿន, កុយ ធួន, ចក្រី។ តើវាអាចដែរទេ ដែលថាព័ត៌មាននេះ វាចេញមកអង្គប្រជុំមួយដែលមេកងពលថ្មីហ្នឹងហៅទៅប្រជុំ ហើយចាក់ខ្សែអាត់សំឡេងហ្នឹងឲ្យលោកស្តាប់។

តើវាអាចថាអ៊ីចឹងដែរឬទេ?

**ឆ៖** ខ្ញុំឆ្លើយវាអស់ហើយលោកតុលាការ បានជាខ្ញុំវាមិនដឹងធ្វើម៉េចរួចទៀតនោះ។

**ស៖** លោកសាក្សី អ៊ីចេះ យើងចង់សួរលោកនេះ ដោយសារថាហេតុអី បានជាលោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា មានផែនការធ្វើរដ្ឋប្រហារ វាយដណ្ដើមយកទីក្រុងភ្នំពេញ។ អ៊ីចឹង សំណួររបស់ខ្ញុំងាយៗទេ។ <តើវាអាចទៅរួចទេ>ថា<>ចម្លើយ<ដែលលោក>ឆ្លើយជូនទៅមជ្ឈមណ្ឌលឯក-សារកម្ពុជា <គឺលោកបានឮ>តាមរយៈមេបញ្ជាការកងពលថ្មី <ដែលចាក់ផ្សាយសំឡេងឆ្លើយសារភាពរបស់ អឿន ឱ្យលោកស្ដាប់>?

**ឆ៖** ខ្ញុំវាមិនដឹងហើយនេះនោះ។

[១៣:៤៩:៣០]

**ស៖** លោកសាក្សី ខ្ញុំចង់សួរលោកអំពីឯកសារមួយចំនួន ពាក់ព័ន្ធទៅនឹងបញ្ហាដែលយើងកំពុងតែនិយាយគ្នានេះ។ ទី១ លោកប្រធាន នេះគឺឯកសារ -- បាទ ខ្ញុំសូមអានសម្រង់មួយឱ្យសាក្សីស្ដាប់ពីឯកសារ E3/810 – E3/810។ នេះគឺជាកំណត់ហេតុចុះថ្ងៃទី១៩ <កញ្ញា> ១៩៧៦ នៃកិច្ចប្រជុំរបស់លេខាកងពល ដែលលេខាកងពល៣១០ ឈ្មោះ អឿន នេះបានរាយការណ៍មក សុន សេន <និងអ្នកផ្សេងទៀតនៅក្នុង>អង្គប្រជុំ <ដែលធ្វើឡើងនៅក្នុងកងពលរបស់គាត់>។ ERN ខ្មែរ 00052393 ដល់ 94, អង់គ្លេស 00195344 ដល់ 45, បារាំង 00195359 ដល់ 60។ លោកសាក្សី ឯកសារនេះ គឺជារបាយការណ៍មួយដែលធ្វើឡើងដោយមេកងពលរបស់លោកនៅក្នុងខែកញ្ញា ១៩៧៦ ផ្ញើជូនមក សុន សេន និងមេបញ្ជាការកងពលដទៃទៀត។ នៅត្រង់កថាខណ្ឌ៤នៃរបាយការណ៍របស់ អឿន នេះ គឺគាត់និយាយអំពីស្ថានភាពសុខភាពនៅក្នុងកងពលរបស់លោក ហើយដែលគាត់បានរាយការណ៍ដូចតទៅ៖ "បងប្អូនយើង២.៦០០នាក់ឈឺ ជាង៤០០នាក់ឈឺធ្ងន់មែនទែន មិនអាចធ្វើការបាន"។ បន្ទាប់មកទៀត "នៅក្នុងខែនេះ កងទ័ពប្រាំពីរនាក់នៅក្នុងកងពិសេស<និង>កងកាំភ្លើងធំ បានស្លាប់ដោយសារតែមូសខាំ ដោយសារតែផឹកទឹកមិនស្អាត ហើយដោយសារតែ<រស់នៅតំបន់>គ្រុនចាញ់<>ដូចជាកប់ស្រូវ <និងពូនភ្នំ>"។ ហើយកថាខណ្ឌបន្ទាប់មកទៀត អឿន បានរាយការណ៍ថា "របបអាហារផ្គត់ផ្គង់មកទាំងអស់ <នឹង>ហូបអស់ហើយ នៅក្នុងខែកញ្ញានេះ"។ បញ្ចប់ការដកស្រង់។

លោកសាក្សី ខ្ញុំសួរលោកអំពីសម្រង់នេះ ដោយសារតែលោកបានបញ្ជាក់ថា កងរបស់លោកនេះគេបានបញ្ជូនទៅឱ្យលត់ដំនៅការដ្ឋានកប់ស្រូវ។ អ៊ីចឹងសំណួររបស់ខ្ញុំថា នៅក្នុងខែកញ្ញា ១៩៧៦ អឿន

បានរាយការណ៍មកថៅហ្វាយនាយរបស់គាត់ អំពីជំងឺគ្រុនចាញ់នៅកប់ស្រូវ។ តើកងរបស់លោក ត្រូវបានបញ្ជូនទៅកប់ស្រូវនៅពេលណា? តើនៅមុន<ថ្ងៃទី១៩> ខែកញ្ញា ១៩៧៦ ឬក៏ក្រោយខែកញ្ញា ១៩៧៦? តើលោកចាំទេថា គេបញ្ជូនលោកទៅតំបន់កប់ស្រូវនេះ នៅពេលណាដែរ?

**ឆ៖** ក្រោយគេ ចាប់មេកងពលហ្នឹងទៅ។

[១៣:៥៣:១៣]

**ស៖** នៅៗកថាខណ្ឌ៦ នៃរបាយការណ៍នេះ គឺលេខាកងពល អឿន នេះ បានរាយការណ៍ជូន សុន សេន នៅថ្ងៃទី១៩ កញ្ញា ៧៦ គាត់បានរាយការណ៍ដូចតទៅ៖ "ក្រោយពីលត់ដំរួចមក គឺថាមានការបះបោរផ្ទៃក្នុងយ៉ាងខ្លាំង សមាជិកកម្មាភិបាលមួយចំនួននោះ គឺថាមិនស្មោះត្រង់នឹងបក្សទេ ហើយកំពុងតែក្បត់ជាមួយនឹងបក្ស គឺៗថា ពួកគេមិនសប្បាយចិត្តជាមួយនឹងផែនការ៤ឆ្នាំរបស់បក្សនោះទេ។" បញ្ចប់ការដកស្រង់។

មូលហេតុដែលខ្ញុំលើកចំណុចនេះយកមកសួរលោក លោកសាក្សី គឺថាចម្លើយរបស់លោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយនិងចម្លើយដែល<>យកមកសួរ<លោក>ដោយមេធាវីការពារក្តីនេះ បញ្ជាក់ថា អឿន មានការជាប់ពាក់ព័ន្ធនៅក្នុងផែនការធ្វើរដ្ឋប្រហារ<ប្រឆាំងបក្ស>។ <ហើយនៅក្នុងឯកសារនេះ> អឿន បានប្រាប់ទៅ សុន សេន <>ដោយបើកចំហថា <>កម្មាភិបាលមួយចំនួននៅក្នុងកងពលនេះ មិនសប្បាយចិត្តនឹងផែនការរបស់បក្សទេ <ហើយក្បត់បក្ស>។ តើលោកយល់យ៉ាងដូចម្តេចដែរ ចំពោះសម្តីមេកងពលរបស់លោកនេះ? ប្រសិនបើ អឿន នេះមានការចូលរួមពាក់ព័ន្ធនៅក្នុងផែនការធ្វើរដ្ឋប្រហារក្បត់បក្សជាសម្ងាត់នោះ ហេតុអីបានជាគាត់ប្រាប់ឲ្យមជ្ឈិមបក្សនេះ ដឹងថាកងទ័ពរបស់គាត់នេះមិនសប្បាយចិត្ត ហើយកំពុងតែក្បត់ជាមួយនឹងបក្ស? តើលោកយល់ដូចម្តេចដែរ ចំពោះសម្តីមេកងពលរបស់លោកនេះ?

[១៣:៥៥:០១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី នួន ជា!

**លោក វ៉ិចទ័រ កូប៉េះ៖**

ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ។ សាក្សី គាត់មិនអាច<និយាយអំពីអ្វីដែលជា>គំនិត<របស់ អឿន នៅក្នុងអង្គប្រជុំនោះបានទេ។ ហើយប្រាកដណាស់> បើសិនជា អឿន ពាក់ព័ន្ធទៅនឹងការធ្វើរដ្ឋ

ប្រហារ ម៉េចក៏ប្រាប់ទៅ សុន សេន នោះទៅវិញ។ អ៊ីចឹងសំណួរបែបនេះគឺមិនត្រឹមត្រូវទេ ការសួរបែបនេះ ជាការសួរឲ្យសាក្សីឆ្លើយដោយស្មានៗ គិតថាតើ អឿន នេះកំពុងតែចង់និយាយអំពីអ្វីនោះ?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកសហព្រះរាជអាជ្ញារងអន្តរជាតិប្រហែលជាលោកអាចនឹងរៀបសំណួរឡើងវិញ មើលទៅដោយសារតែលោកសួរឲ្យសាក្សីឆ្លើយស្មានហើយ។

[១៣:៥៥:៥១]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ខ្ញុំសូមរៀបសំណួរឡើងវិញ។ នេះគឺជាឯកសារចុះខែកញ្ញា ៧៦ ដែលលេខាកងពលរបស់លោកបានរាយការណ៍មកដល់ សុន សេន ដែលថាមានកម្មាភិបាលក្នុងកងពលមិនសប្បាយទៅនឹងគោលនយោបាយរបស់បក្សទេ ហើយកំពុងតែក្បត់បក្សហើយ។ តើលោកចាំទេ ថានៅចុងឆ្នាំ៧៦ ឬក៏ដើមឆ្នាំ៧៧ មានតំណាងម្នាក់ចេញពីនាយ ពីអគ្គសេនាធិការឲ្យទៅកងពលពិនិត្យមើលប្រវត្តិរូបក្នុងកងពលរបស់លោកថាអ្នកណាក្បត់ខ្លះ? តើលោកនៅចាំទេថា គេមានបញ្ជូនមនុស្សម្នាក់ពីអគ្គសេនាធិការទៅហ្នឹង ឲ្យទៅពិនិត្យប្រវត្តិរូបយុទ្ធជននៅក្នុងកងពលរបស់លោក ដើម្បីពិនិត្យមើលអ្នកណាក្បត់ អ្នកណាមិនក្បត់ លោកចាំទេ?

**លោក ស៊្វី សៅ៖**

**ឆ៖** ខ្ញុំមិនចាំទេ បើខ្ញុំអាល័យតែធ្វើស្រែកប់ស្រូវនោះ។

[១៣:៥៧:០៥]

**ស៖** ឥឡូវខ្ញុំសូមសួរពីឈ្មោះមនុស្សដែលទៅពីខាងអគ្គសេនាធិការទៅ។ <>

បើលោកប្រធានមានឯកសារមួយចំនួន ដែលកត់ត្រាឈ្មោះមនុស្សម្នាក់ឈ្មោះ រ៉េន។ រ៉េន នេះបានគឺមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះម្តងរួចទៅហើយ។ ឯកសារចុះខែ<វិច្ឆិកា> ១៩៧៦ និងខែមីនា ១៩៧៧ គាត់បានរាយការណ៍អំពីកិច្ចខិតខំប្រឹងប្រែង ដើម្បីពិនិត្យតាមដានក្តាប់ប្រវត្តិរូបនៅក្នុងកងពលនោះ គឺឯកសារ E3/1131 និងឯកសារ E3/1161។ នៅក្នុងសវនាការយើង<ឬនៅក្នុងសវនាការទី១> គាត់បានផ្តល់សក្ខីកម្មថាគាត់ត្រូវបានចាត់តាំងទៅឲ្យតាមដាន និងក្តាប់ប្រវត្តិរូបសមាជិកកងពលនេះ។ គាត់បានមកឆ្លើយនៅថ្ងៃទី១០ ខែមករា <២០១៣> <នៅម៉ោង១០:១៦ នាទីព្រឹក>។ សំណួររបស់ខ្ញុំ ដំបូងសួរថាតើលោកនេះ ចាំមនុស្សម្នាក់ទេឈ្មោះ រ៉េន ទៅពីខាងអគ្គសេនាធិការដ្ឋានទៅ

ដែលគេបានចាត់តាំងតាងនាមឲ្យអគ្គសេនាធិការទៅក្តោបក្តាប់ប្រវត្តិរូបនៅក្នុងកងពលរបស់លោក លោកចាំមនុស្សម្នាក់នេះទេ?

**ឆ៖** ខ្ញុំមិនចាំទេ បើខ្ញុំមិនដឹងសោះហើយ។

[១៣:៥៨:៥០]

**ស៖** ព្រឹកមិញនេះ ខ្ញុំបានសួរលោកថាតើមានយុទ្ធជនច្រើនដែរឬទេ នៅក្នុងកងពលរបស់លោក នេះ ដែលត្រូវចាប់គេចាប់ខ្លួន បន្ទាប់ពីគេចាប់ខ្លួនតាអឿន រួចមក។ អ៊ីចឹងខ្ញុំសូមសួរឈ្មោះមនុស្សម្នាក់ ឲ្យបានជាក់លាក់។

**លោក ខេល លីសាក់៖**

លោកប្រធាន សូមការអនុញ្ញាតផ្តល់ឯកសារបញ្ជីឈ្មោះអ្នកទោសស-២១ គឺ E3/9954 ហើយ ទំព័រដែលខ្ញុំចង់សួរខ្មែរគឺ 01012060។ នេះគឺជាឯកសារថ្មីមួយរបស់សហចៅក្រមស៊ើបអង្កេត គឺ ឯកសារ E3/9954 សូមផ្តល់ឯកសារនេះឲ្យសាក្សីពិនិត្យមើល។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការយកឯកសារជូនទៅសាក្សី។

[១៥:៥៩:៥៨]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកសាក្សី ខ្ញុំបានគូសចំឈ្មោះមនុស្សដែលខ្ញុំត្រូវសួរលោក។ សូមលោកមើលចំឈ្មោះ ហ្នឹង គឺមានលេខរៀង៣៤៧ ឈ្មោះ អ៊ិន ឈន ជាយុទ្ធជនមកពីអនុសេនា<ធំលេខ>១ វរសេនាតូច ១១២ <ដែលជាអនុសេនាធំ និងវរសេនាតូចរបស់លោក>។ គាត់បានចូលមកស-២១ នៅថ្ងៃទី<១៤> កក្កដា ៧៧ ហើយត្រូវបានសម្លាប់នៅថ្ងៃ១៦ កក្កដា ៧៧។ នៅក្នុង ឯកសារនេះ គឺគាត់មានលេខនៅក្នុង បញ្ជីថ្មីរបស់សហចៅក្រមស៊ើបអង្កេត គាត់មានលេខរៀង៥០០៩។ លោកសាក្សី លោកចាំទេ មនុស្ស ម្នាក់នេះឈ្មោះ អ៊ិន ឈន នេះមកពីកងអនុសេនាធំរបស់លោក គឺថាគេបានចាប់ខ្លួនមកស-២១ លោក ស្គាល់មនុស្សម្នាក់ទេ?

**លោក ស៊ួយ សៅ៖**

**ឆ៖** បាទ ខ្ញុំមិនស្គាល់សោះនោះ។

**ស៖** ចុះលោកមានចាំថាមានអ្នកណានៅក្នុងកងអនុសេនា<ធំ>របស់លោកហ្នឹងត្រូវបានចាប់

ខ្លួន <ហើយបាត់ខ្លួន>ដែរឬទេនៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ<> ជាពិសេស គឺក្នុងឆ្នាំ ១៩៧៧?

**ផ៖** អានោះ គេចាប់ពីកងតូចកងធំអស់រលីងទៅហើយ នៅតែយុទ្ធជនខ្ញុំអត់មានដឹងបញ្ហាអីទាំងអស់។

[១៤:០២:១៣]

**ស៖** ឥឡូវខ្ញុំចូលទៅប្រធានបទមួយថ្មីសន្លាងតែម្ដង។ នេះគឺការប្រាស្រ័យទាក់ទងរបស់លោកជាមួយនឹងថ្នាក់ដឹកនាំជាន់ខ្ពស់។ នៅពេលលោកឈរជើងនៅភ្នំពេញជាមួយកងពល៣១០ តើលោកមានដែលបានឃើញថ្នាក់ដឹកនាំណាម្នាក់បើកអង្គប្រជុំនៅស្ដាតអូឡាំពិកនោះដែរឬទេ? ហើយបើមានមែនសូមលោកជម្រាបជូនអង្គជំនុំជម្រះលម្អិតបន្តិច។

**ផ៖** ខ្ញុំវាមិនដែលបានទៅប្រជុំស្ដាតអូឡាំពិកនឹងគេផងហ្នឹងណា។

**ស៖** នៅក្នុងអំឡុងពេលដែលលោកឈរជើង<នៅភ្នំពេញ>ចំណុះឲ្យកងពល៣១០ហ្នឹង លោកដែលបានឃើញ ខៀវ សំផន ដែរទេ?

**ផ៖** ខ្ញុំមិនដែលឃើញទេ បើខ្ញុំនៅឯជនបទនោះ វាមិននៅចំតួទីក្រុងឯណា អត់។

**ស៖** ឥឡូវខ្ញុំសូមដកស្រង់ចម្លើយរបស់លោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា។ លោកប្រធាន ខ្ញុំ<នឹងអានពី>ឯកសារ E3/7535, ERN ជាភាសាខ្មែរ 00087815 ដល់ 16, អង់គ្លេស 00324166 ដល់ 67, បារាំង 00324204 ដល់ 05។ នេះគឺជាចម្លើយរបស់លោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា លោកសាក្សី "សួរ៖ នៅពេលគេបើកអង្គប្រជុំនៅស្ដាតអូឡាំពិកនោះ តើ<គេធ្លាប់ហៅ>លោក<ទៅ>ប្រារព្វរំឭកខួបជ័យជម្នះ<ទេ>? ឆ្លើយ៖ ពួកគេប្រារព្ធខួប០៧ មករា ឬ១៧ មេសា <នៅស្ដាតអូឡាំពិក>។ <សួរ៖> តើ<លោក>មាន<ឃើញ>មេដឹកនាំថ្នាក់ជាន់ខ្ពស់ចូលរួមដែរឬទេ? ឆ្លើយ៖ បាទ មាន ខៀវ សំផន។" ហើយបន្តមកខាងក្រោយទៀតនៅក្នុងកិច្ចសម្ភាសន៍ត្រង់ទំព័រដដែលហ្នឹង ក្រោយគេសួរថាតើអង្គប្រជុំហ្នឹងមុន ឬក៏ក្រោយការចាប់ខ្លួន អឿន? សួរ៖ តើគេប្រារព្ធធ្វើអង្គប្រជុំនៅស្ដាតអូរឡាំពិកហ្នឹង មុនពេលគេចាប់ខ្លួន អឿន ឬ? ឆ្លើយ៖ គេបញ្ជូនឲ្យខ្ញុំទៅទទួលភ្ញៀវនៅទីនោះ។ <សួរ៖> តើលោកទៅទទួលភ្ញៀវហ្នឹងជាអ្នកណា? ឆ្លើយ៖ ខៀវ សំផន។ សួរ៖ តើ ខៀវ សំផន ទៅធ្វើអ្វីនៅទីនោះ? <តើលោកបានទៅចូលរួមការប្រជុំនោះទេ?> ឆ្លើយ៖ បាទ អង្គប្រជុំហ្នឹងគេធ្វើនៅក្នុងសាលារៀនមួយ។ សួរ៖ តើគេប្រារព្ធអង្គប្រជុំបែបនេះនៅស្ដាតអូរឡាំពិកប៉ុន្មាន

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដងដែរ? ឆ្លើយ៖ បីដង។ សួរ៖ បីដងឬ? តើលោកបានឃើញ ខៀវ សំផន ប៉ុន្មានដង? ឆ្លើយ៖ បានឃើញពីរដង។" បញ្ចប់ការដកស្រង់។ តើចំណុចនេះ វាជួយរំឭកដល់ការចងចាំរបស់លោកទេលោកសាក្សី តើលោកពិតជាបានឃើញ ខៀវ សំផន នៅក្នុងពិធីប្រារព្ធខួបជ័យជម្នះនៅស្តាតអូឡាំពិកនោះមែនឬ?

[១៤:០៦:០៥]

**ឆ៖** បាទ ខ្ញុំមិនមែន *(ឮមិនច្បាស់)* ទើបតែក្រោយ ខ្ញុំមិនបានទៅចូលរួមប្រជុំទេណា អត់។

**ស៖** លោកក៏បានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជាផងដែរ ថានៅក្នុងអំឡុងពេលនោះគឺលោកទទួលខុសត្រូវយាមភ្ញៀវបរទេស នៅពេលដែលគេទទួលភ្ញៀវបរទេស គឺថាលោកជាអ្នកយាមការពារភ្ញៀវបរទេស។ តើអ៊ីចឹងមែនទេ នៅពេលដែលលោកឈរជើងនៅភ្នំពេញ លោកធ្វើការងារនេះមែនទេ?

**ឆ៖** បាទ អាហ្នឹងខ្ញុំយាមអ៊ីចឹងមែនបាទ។

**ស៖** នៅពេលដែលលោកយាមការពារ នៅពេលដែលគេទទួលភ្ញៀវបរទេសនោះ តើមេដឹកនាំខ្មែរក្រហមដែលទទួលភ្ញៀវបរទេសហ្នឹងជាអ្នកណាដែរ?

**ឆ៖** ខ្ញុំក៏មិនដឹងដែរអាហ្នឹងឯង ខ្ញុំចេះតែគិត គេឱ្យទៅចេះតែទៅៗបាទ។

[១៤:០៧:៣១]

**ស៖** បាទ សូមអានសម្រង់មួយទៀត លោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជាដែរ។ នៅឯកសារដដែលហ្នឹងគឺ E3/7535, ERN ជាភាសាខ្មែរ 00087820, អង់គ្លេស 00324170, បារាំង 00324208 ដល់ 09។ "សួរ៖ តើមេដឹកនាំខ្មែរជាន់ខ្ពស់បំផុតដែលទៅទទួលភ្ញៀវបរទេសហ្នឹងជាអ្នកណា? ឆ្លើយ៖ ជាញឹកញាប់ ខ្ញុំឃើញ ខៀវ សំផន"។ បញ្ចប់ការដកស្រង់។ តើលោកពិតជាបានឃើញ ខៀវ សំផន ទៅទទួលបដិសណ្ឋារកិច្ច ទៅទទួលភ្ញៀវបរទេសមែនទេ?

**ប្រធានអង្គជំនុំ៖**

សូមឆ្លើយដើមបណ្តឹងរដ្ឋប្បវេណី -- សាក្សី!

**លោក ស៊្វយ សៅ៖**

**ឆ៖** ខ្ញុំមិនសូវដឹងដែរបាទ។ បើខ្ញុំនៅក្មេងខ្ចីដែរ ដែលវាតូចតាចជាងគេ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ហេតុអ្វីបានជាលោកប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថាលោកឃើញ ខៀវ សំផន ញឹក

ញាប់នោះ បើលោកមិនបានឃើញផងនោះ?

**ឆ៖** បើខ្ញុំវាមិនសូវបានឃើញមែន អ៊ីចឹងថាឲ្យឃើញយ៉ាងម៉េច។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសូមកាត់បន្តិច លោកសាក្សីពេលគេសម្ភាសលោក ពេលគេធ្វើគេសម្ភាសចប់។ តើលោកមានបានអានឯកសារដែលគេសម្ភាសលោកកាលពីពេលហ្នឹងទេ?

**លោក ស៊្វុយ សៅ៖**

បាទ ខ្ញុំអានហើយបាទ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមានមើលឃើញថាមានព័ត៌មានណាមួយដែលមិនត្រឹមត្រូវទេពេលដែលលោកអានកំណត់ហេតុសម្ភាសន៍លោកហើយនោះ?

[១៤:១០:០៦]

**លោក ស៊្វុយ សៅ៖**

មើលទៅវាសមស្របតាមគ្នាហើយបាទ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

បញ្ហាគឺថា នៅទីនេះ ថ្ងៃនេះ លោកបានរៀបរាប់រឿងរ៉ាវផ្សេង ពីអ្វីដែលលោកបានផ្ដល់ជូនបទសម្ភាសន៍ទៅមជ្ឈមណ្ឌលឯកសារកម្ពុជានោះ ហើយកាលពីព្រឹកមិញនេះ លោកអាចនឹកឃើញរឿងបានច្រើន ក៏ប៉ុន្តែមកដល់រសៀលនេះ លោកបែរជានឹកអ្វីមិនឃើញ លោកឆ្លើយតែថាលោកមិនដឹង។ អ៊ីចឹងខ្ញុំសូមសង្ខេបឡើងវិញ ពេលដែលលោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា តើលោកនិយាយការពិតទេ?

**លោក ស៊្វុយ សៅ៖**

បាទ ខ្ញុំនិយាយអស់ការពិតប៉ុណ្ណេះឯងហើយ ខ្ញុំ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ៊ីចឹង ពេលនោះគឺ១០ឆ្នាំមុន លោកនិយាយការពិតប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយលោកអានកំណត់ហេតុសម្ភាសហ្នឹងក្រោយពីពេលដែលគេសម្ភាសចប់ តើត្រឹមត្រូវទេ?

**លោក ស៊្វួយ សៅ៖**

បាទ ត្រឹមត្រូវហើយ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ៊ីចឹងគឺថាអ្វីៗក្នុងកំណត់ហេតុហ្នឹងគឺត្រឹមត្រូវទាំងអស់ លោកអត់មានបានកែប្រែអ្វីទេ មែនទេ?

**លោក ស៊្វួយ សៅ៖**

បាទ ខ្ញុំគ្មានកែប្រែងណាបាទ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ៊ីចឹងលោកពន្យល់ទៅមើល ហេតុអ្វីបានជាលោកឆ្លើយនៅថ្ងៃនេះ វាខុសពីអ្វីដែលលោកបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជាកាលពី១០ឆ្នាំមុន?

**លោក ឌេល លីសាក់៖**

សូមអរគុណលោកស្រីចៅក្រម ហ្វេនស៍។

[១៤:១១:៥៩]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ខ្ញុំបានអានឲ្យលោកស្ដាប់ នូវចម្លើយរបស់លោកដែលបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយពេលនោះ លោកឆ្លើយថាលោកឃើញលោក ខៀវ សំផន ទាំងនៅស្ពានអូឡាំពិកដែលគេរៀបចំពិធីប្រជុំរំឭកខួប ហើយ<ទាំង>នៅពេលដែលលោកធ្វើជាអ្នកយាមទៅទទួលភ្ញៀវ <ហើយនៅពេលនោះលោកធ្វើជាអ្នកយាម>។ តើរឿងនេះ រឿងដែលលោករៀបរាប់ជូនមជ្ឈមណ្ឌលឯកសារកម្ពុជានេះជារឿងពិត ឬក៏មិនពិត?

**លោក ស៊្វួយ សៅ៖**

**ឆ៖** បាទ រឿងនោះ មិនពិតទេបាទ។

**ស៖** ដូច្នេះមានន័យថា ចម្លើយដែលលោកឆ្លើយថា លោកបានឃើញ ខៀវ សំផន នៅក្នុងឯកសាររបស់មជ្ឈមណ្ឌលកម្ពុជានោះ គឺថាមិនត្រឹមត្រូវទេ មែនទេ?

**ឆ៖** បាទ។

**ស៖** ចុះចម្លើយដែលលោកបានរៀបរាប់ជូនមជ្ឈមណ្ឌលឯកសារកម្ពុជាថា លោកបានចូលរួមប្រជុំជាមួយ តាអឿន នៅពេលដែលគេ<>និយាយអំពីផែនការរដ្ឋប្រហារនោះ ចំណុចនេះត្រឹមត្រូវទេ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឬក៏លោកមិនបានចូលរួមប្រជុំជាមួយ តាអឿន ទេ?

**ឆ៖** បាទ យើងខ្ញុំមិនដែលបានចូលរួមប្រជុំជាមួយមេកងពលផង ព្រោះខ្ញុំយុទ្ធជនគេដែលហៅទៅទេបាទ។

**ស៖** បាទ មិនអីទេ អ៊ីចឹង។ ឥឡូវខ្ញុំចូលទៅប្រធានបទមួយទៀតដែលលោកបាននិយាយកាលពីព្រឹកមិញហើយ ថាតើក្នុងឆ្នាំ៧៨ កងរបស់លោកហ្នឹងត្រូវបានបញ្ជូនទៅសមរភូមិ នៅភូមិភាគបូព៌ាដើម្បីប្រយុទ្ធជាមួយនឹងកងទ័ពវៀតណាម។ នៅពេលដែលលោកនៅសមរភូមិនៅឆ្នាំ៧៨ តើមានចាប់ទាហានវៀតណាមបានទេ ហើយបើចាប់បាននោះ តើលោកធ្វើយ៉ាងម៉េចចំពោះទាហានវៀតណាមទាំងនោះ?

**ឆ៖** ខ្ញុំមិនដែលបានចាប់បានកងទ័ពវៀតណាមទេខ្ញុំនោះ។

[១៤:១៤:៥១]

**ស៖** ខ្ញុំចង់និយាយអំពីចាប់បានពេលវ៉ៃប្រយុទ្ធគ្នានោះ លោកដឹងទេ ថាពេលដែលវាយប្រយុទ្ធគ្នាហ្នឹង មានបានចាប់ទាហានវៀតណាមណាទេ ហើយបើចាប់បានគេធ្វើយ៉ាងម៉េចចំពោះទាហានទាំងនោះ?

**ឆ៖** ខ្ញុំនៅខាងក្រោយនោះ ម៉េចបានចាប់បានកងទ័ពវៀតណាមនោះ បើនៅឯភូមិក្រោយ។

**ស៖** ឥឡូវនេះខ្ញុំសូមអានចម្លើយរបស់លោកជូនជម្លមណ្ឌលឯកសារកម្ពុជា ឯកសាE3/7535 ភាសាខ្មែរ <00087832>, អង់គ្លេស 00324180, បារាំង <00324222>។ "សួរ៖ ក្នុងពេលប្រយុទ្ធគ្នា តើលោកមានចាប់បានយុទ្ធជនវៀតណាមណាទេ? ឆ្លើយ៖ បាទ យើងចាប់បានខ្លះ។ សួរ៖ តើលោកធ្វើយ៉ាងម៉េច ចំពោះអ្នកដែលចាប់បានហ្នឹង? ឆ្លើយ៖ គេបញ្ជូនអ្នកទាំងហ្នឹងតាមឡានទៅភ្នំពេញ។" សូមបញ្ចប់ការដកស្រង់។ លោកសាក្សី នេះជាផ្នែកមួយនៃចម្លើយដែលលោកបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា។ តើចម្លើយនេះជាចម្លើយត្រឹមត្រូវ ឬក៏លោកមិនបានដឹងអ្វីទេ ពាក់ព័ន្ធនឹងការចាប់ខ្លួនវៀតណាមនេះ? បាទ សូមកែតម្រូវឯកសារជាភាសាគឺ 00324180។

**ឆ៖** ពិបាកនិយាយ មិនដឹង។ ខ្ញុំបាទមិនដឹង ខ្ញុំចាប់ម៉េច។ បើដឹងថាដឹង បើមិនដឹងថាមិនដឹងហ្នឹងហើយ។

[១៤:១៧:០៧]

**ស៖** ដូច្នេះ លោកកំពុងតែនិយាយថា ផ្នែកនៃចម្លើយដែលលោកបានឆ្លើយជូនជម្លមណ្ឌលឯក-

សារនេះ គឺមិនត្រូវទេ។ អ៊ីចឹងមែនទេ?

**ឆ៖** មិនត្រឹមត្រូវទេបាទ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោក<មិន>អាច<ឆ្លើយពីរផ្លូវដូច្នេះបានទេ។ លោកទើបតែ>ប្រាប់ខ្ញុំថា <ចម្លើយដែលលោកផ្តល់ជូនមជ្ឈមណ្ឌលឯកសារកម្ពុជានោះគឺត្រឹមត្រូវ> ព្រោះថាពេលនុ៎ង លោកថាលោកបានអានមើលហើយ លោកអត់មានកែអីទេ ហើយដល់ពេលឥឡូវលោកថាមិនត្រឹមត្រូវ ដល់អ៊ីចឹងយ៉ាងម៉េចនេះឥឡូវនេះ?

**<លោក វិចទ័រ កូប៉េះ>**

<វាមិនមែនទាំងពីរ។ វាមិនមែនជម្រើសទាំងពីរទេ។ ពិតប្រាកដណាស់ មានអ្វីបានកើតឡើងនៅពេលសម្រាកអាហារថ្ងៃត្រង់ហើយ។>

**<ចៅក្រម ក្លូឌា ហ្វេនស៍៖>**

<សូមឲ្យខ្ញុំបញ្ចប់សិន។>

**លោក វិចទ័រ កូប៉េះ**

<គួរតែសួរគាត់ថា មានអ្វីបានកើតឡើង។> បាទ ខ្ញុំដឹងថាប្រហែលជាមានរឿងអីកើតឡើងនៅពេលឈប់សម្រាកអាហារថ្ងៃត្រង់ហើយ។ អ៊ីចឹងប្រហែលជាមានបញ្ហានៅពេលឈប់សម្រាកអាហារថ្ងៃត្រង់នោះ បានជាគាត់ឆ្លើយអ៊ីចឹង។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១៩:៥២]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី ចាប់ពីនេះតទៅ។

*(សវនាការសម្រាកនៅម៉ោង ១៤:២០ នាទី ដល់ម៉ោង ១៤:៤៥នាទី)*

[១៤:៤៥:២២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះសម្រេចធ្វើសវនាការជាអសាធារណៈ ដើម្បីកំណត់ថាតើធ្វើសវនាការបន្តទៅទៀត

ជាសាធារណៈ ឬក៏អសាធារណៈ។ បង្គាប់ឲ្យមន្ត្រីផ្នែកសោតទស្សន៍ផ្ដាច់សំឡេងទៅសាលសាធារណៈ និងបន្ទប់ប្រព័ន្ធផ្សព្វផ្សាយ។ សូមអញ្ជើញ!

*(សវនាការសាធារណៈផ្អាកនៅម៉ោង ១៤:៤៧ នាទី)*

*(សវនាការអសាធារណៈចាប់ផ្ដើមពីម៉ោង ១៤:៤៧ នាទី និងបញ្ចប់នៅម៉ោង ១៥:០៦ នាទី)*

*(សវនាការសាធារណៈបន្តនៅម៉ោង ១៥:០៦ នាទី)*

[១៥:០៦:១៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញាបន្តសំណួរ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរបន្តដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សីមុននឹងខ្ញុំបញ្ចប់សំណួររបស់ខ្ញុំនេះទៅ គឺថាខ្ញុំសួរប្រធានបទមួយថ្មីទៀត។ នេះគឺពាក់ព័ន្ធទៅនឹងអំឡុងពេលដែលគេបញ្ជូនលោកទៅភូមិភាគបូព៌ានៅឆ្នាំ១៩៧៨។ នៅពេលដែលលោកនៅឯភូមិភាគបូព៌ាក្នុងឆ្នាំ១៩៧៨ តើលោកមានធ្លាប់បានឃើញការសម្លាប់អ្នកដែលជាប់ពាក់ព័ន្ធទៅជាមួយនឹងលេខាភូមិភាគបូព៌ា គឺ សោ ភឹម ដែរទេ?

**លោក ស៊្វីយ សៅ៖**

**ឆ៖** ខ្ញុំមិនដែលឃើញផងបាទ។

[១៥:០៧:៣៨]

**ស៖** ខ្ញុំមិនបានសួរលោកថា តើលោកបានឃើញ សោ ភឹម ឬក៏បានឃើញគេសម្លាប់ សោ ភឹម នោះទេ។ ខ្ញុំសួរថាតើលោកធ្លាប់បានឃើញគេសម្លាប់អ្នកដែលជិតដិត ឬក៏មានទំនាក់ទំនងជាមួយ សោ ភឹម ដែរទេ? ដូចជាកងការពារ ឬក៏ជានីរសាររបស់ សោ ភឹម ជាដើម។ ខ្ញុំសំដៅទៅលើមនុស្សទាំងឡាយណាដែលមានទំនាក់ទំនងជាមួយនឹង សោ ភឹម តើលោកធ្លាប់ដែលគេឃើញ ដែលឃើញគេសម្លាប់អ្នកទាំងនោះដែរទេ?

**ឆ៖** ខ្ញុំមិនដែលឃើញផង ព្រោះខ្ញុំនៅឯក្រោយនេះបាទ។

**ស៖** បាទ ឥឡូវខ្ញុំសូមបង្ហាញលោកនូវសម្រង់មួយគឺ E3/7535 ដដែលនេះ ERN ជាភាសាខ្មែរ

00087838, អង់គ្លេស 00324184, បារាំង 00324226 ដល់ 27។ នេះគឺជាប្រតិចារឹករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាពាក់ព័ន្ធទៅនឹងកិច្ចសម្ភាសន៍របស់លោក។ “សួរ៖ ក្រោយពេលចាប់ សោ ភឹម <ត្រូវ>បាន<គេចាប់ខ្លួន> តើគេមានចាប់ផ្តើមធ្វើការបោសសម្អាតដែរឬទេ? ឆ្លើយ៖ បាទ គេចាប់ផ្តើមបោសសម្អាតខ្សែរបស់ សោ ភឹម ទាំងអស់។ សួរ៖ តើគេបោសសម្អាតដោយការ<ហៅទៅ>អប់រំ ឬក៏ដោយមធ្យោបាយណាផ្សេង? ឆ្លើយ៖ អ្នកខ្លះគេយកទៅសម្លាប់ចោល។ ជាពិសេសអ្នកដែលចូលរួមពាក់ព័ន្ធដោយសកម្ម។ សួរ៖ តើលោកបានឃើញរឿងរាវទាំងអស់នោះទេ? ឆ្លើយ៖ បាទ ខ្ញុំបានឃើញគេសម្លាប់មនុស្ស។ សួរ៖ គេសម្លាប់នៅឯណា? ឆ្លើយ៖ នៅជ្រំ។ សួរ៖ តើគេសម្លាប់មនុស្សដោយរបៀបណា? ឆ្លើយ៖ កងទ័ពភូមិភាគនិរតីបានសម្លាប់ប្រពន្ធរបស់ សោ ភឹម និងនីរសារ សោ ភឹម។” បញ្ចប់ការដកស្រង់។ លោកសាក្សី តើលោកពិតជាបានឃើញការសម្លាប់មនុស្ស គឺការសម្លាប់នីរសាររបស់ សោ ភឹម ឬក៏ពិតជាបានឃើញគេសម្លាប់ប្រពន្ធរបស់ សោ ភឹម មែនឬ?

[១៥:១០:១៨]

**ឆ៖** ខ្ញុំមិនដែលឃើញ ឲ្យខ្ញុំឆ្លើយថាឃើញយ៉ាងម៉េច បើខ្ញុំមកនៅឯក្រោយនេះទេ។

**ស៖** ចុះម៉េចបានជាលោកឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជានោះណ៎ា ថាលោកឃើញកងទ័ពនិរតីនេះសម្លាប់ប្រពន្ធ សោ ភឹម?

**ឆ៖** ហេ! ខ្ញុំមិនបានឆ្លើយពីកាលណា បើខ្ញុំមិនដឹង។

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា។

សូមលោកមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីមានសំណួរដល់សាក្សី។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

បាទ សូមអរគុណលោកប្រធាន។ យើងអត់មានសំណួរអីសួរទៅសាក្សីទេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

[១៥:១១:៣៧]

01354953



**លោក ឌេល លីសាក់៖**

បាទ មានបញ្ហាមួយដែលខ្ញុំចង់សួរទៅតុលាការ។ ការអះអាងរបស់មេធាវីការពារក្ដីមុនពេល <យើងធ្វើសវនាការអសាធារណៈ>នោះ <ខ្ញុំគិតថា>គួរតែជម្រាបជូនទៅសាធារណជនវិញផងដែលថា អង្គជំនុំជម្រះបានសម្រេចបើកសវនាការអសាធារណៈដោយសារតែថារឿងបញ្ហានេះ ហើយសូមប្រាប់អំពីលទ្ធផលនេះ ផង។ <ខ្ញុំគិតថា មិនមានអ្វីសម្ងាត់ក្នុងអំឡុងពេលសវនាការអសាធារណៈនេះទេ។ ប៉ុន្តែខ្ញុំគិតថា វាមានសារសំខាន់ក្នុងការឲ្យសាធារណជនបានដឹងនូវអ្វីដែលសាក្សីបាននិយាយជាការឆ្លើយតបទៅនឹងសំណួររបស់ចៅក្រម។>

**លោក វ៉ិចទ័រ កូប៉េ៖**

<អ៊ីចឹង តើគោលបំណងនៃការធ្វើសវនាការអសាធារណៈគឺដើម្បីអ្វីទៅ? ខ្ញុំចង់និយាយថា> កាលណាសវនាការអសាធារណៈ វាអសាធារណៈហើយ។<>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<គោលបំណងនៃ>ការបើកសវនាការអសាធារណៈអម្បាញ់មិញនេះ គឺ<ដើម្បីរកឲ្យឃើញ ឬដើម្បីសម្រេចលើអង្គហេតុ ថាតើយើងត្រូវបន្តបើកសវនាការអសាធារណៈទៀត ឬក៏អត់ទេ។>

**លោក វ៉ិចទ័រ កូប៉េ៖**

<ខ្ញុំយល់ហើយ ប៉ុន្តែយើងមិនអាចសន្យាជាមួយគាត់ថា អ្វីដែលនិយាយនៅក្នុងសវនាការអសា-ធារណៈ នឹងនៅតែជាអសាធាណារៈ ហើយបន្ទាប់មកដោយសារតែមិនពេញចិត្តចម្លើយរបស់គាត់ស្រាប់តែបំភ្លេចការសន្យាជាមួយគាត់ចោលនោះទេ>។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ខ្ញុំមិនប្រាកដថាតើមានពាក្យថា “ពេញចិត្ត” ឬ “មិនពេញចិត្ត” នេះទេ ប៉ុន្តែខ្ញុំគិតថា> នេះជាវិធីសាស្ត្រមួយទូទៅដែលអនុញ្ញាតឲ្យអង្គជំនុំជម្រះធ្វើយ៉ាងដូច្នេះ។ អ៊ីចឹង យើងត្រូវតែជម្រាបទៅសាធារណជនថា សាក្សីនេះ គឺថាគាត់ឆ្លើយថាគ្មានអ្នកណាម្នាក់មកជួបគាត់ គ្មានអ្នកណាម្នាក់ទាក់ទងតាមមធ្យោបាយណាមួយ គំរាមកំហែងគាត់ ឬអ្វីនោះទេ។ នេះគឺយើងត្រូវតែជម្រាបសាធារណជនថាដូច្នេះ។

[១៥:១៣:១០]

**លោក វ៉ិចទ័រ កូប៉េ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អ៊ីចឹង<ចាប់ពីពេលនេះទៅគ្មានអ្វីត្រូវនិយាយអំពី>ការសន្យា<ជា>មួយ<>សាក្សី<ទៀតទេ>។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

មិនត្រូវយល់ជាបែបអវិជ្ជមានចំពោះសាក្សីរូបនេះទៅលើចំណុចនេះទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ខៀវ សំផន។

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ខ្ញុំអត់មានសំណួរអីទេលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវី។ សវនាការស្ដាប់សក្ខីកម្មសាក្សី ស៊ួយ សៅ ដល់ទីបញ្ចប់ហើយ។ អង្គជំនុំជម្រះអរគុណលោក ស៊ួយ សៅ ដែលបានចំណាយពេលវេលាមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាសាក្សីក្នុងរយៈពេលមួយថ្ងៃនេះ ដែលលោកអាចសម្រាកបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយបុគ្គលិកអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនសាក្សីរូបនេះវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬគោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការនឹងលើកទៅបន្តទៅធ្វើនៅថ្ងៃចន្ទ ទី២២ ខែសីហា ឆ្នាំ២០១៦ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃចន្ទ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-850 តាមរយៈប្រព័ន្ធសោតទស្សន៍ពីខេត្តឧត្តរមានជ័យ ពាក់ព័ន្ធនឹងអង្គហេតុការបោសសម្អាតផ្ទៃក្នុង។ សូមភាគីជ្រាបនិងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃចន្ទ ទី២២ ខែសីហា ឆ្នាំ២០១៦ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សូមអញ្ជើញសម្រាក៕

*(សវនាការផ្អាកនៅម៉ោង ១៥:១៥ នាទី)*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*